# បារមីកថា
# ពុទ្ធាបទាន

វត្តនិគ្រោធវ័ន "គល់ទទឹង"

រៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព
មុនីកោសល្យ **នៅ~ហៃឡុង**

ព.ស ២៥៥២

*មានបំណងនឹងទុកទំព័រនេះឲ្យទំនេរ*

# បារមីកថា ពុទ្ធាបទាន

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## សុមេធកថា

មានសេចក្ដីដំណាលថា កាលតថាគតបួសជាតាបសមានព្រះនាមប្រាកដថា សុមេធៈ តថាគតរំសាយសក់ត្រង់ប្រទេសនោះ (ចន្លោះផ្លូវដែលព្រះអង្គ ធ្វើមិនទាន់បានសម្រេច) ហើយក្រាលចីវរសំបកឈើនិងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ (អធិដ្ឋានថា) សូមព្រះពុទ្ធព្រមទាំងពួកសង្ឃ ជាន់អាត្មាអញយ៉ាងនេះចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់ភក់នោះ ជាប្រយោជន៍ដល់ អាត្មាអញ, អាត្មាអញនឹងប្រាថ្នានូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក និងជាប្រយោជន៍ដល់សព្វសត្វក្នុងត្រៃភព ។ ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ពាក្យនេះថា (ម្នាលភិក្ខុទាំងឡាយ) អ្នកទាំងឡាយ ចូរមើលនូវតាបសនេះ ជាជដិលមាន

តបះដ៏ខ្ពង់ខ្ពស់ តាបសនេះនឹងបានត្រាស់ជា ព្រះពុទ្ធក្នុងលោក ក្នុងកប្ប ប្រមាណមិនបាន អំពីកប្បនេះទៅ ។ សត្វនេះនឹងចេញ ចាកក្រុង ឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតា ថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មក តាមផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ (អង្គុយ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹង បានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះ ជនិកាមាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាម សុទ្ធោទនៈ ឯតាបសនេះនឹងមានឈ្មោះថា ព្រះ គោតម អគ្គសាវកទាំងពីររូបគឺ កោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិន មានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះ អានន្ទ នឹងបំរើព្រះ ជិនស្រីនេះ ។ អគ្គសាវិកា ពីររូបគឺ នាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាស ចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្ត ខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹង

របស់ព្រះមានព្រះភាគនោះហៅថា អស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូបគឺ ចិត្តៈ ១ ហត្ថាឡវកៈ ១ ។ នាងនន្ទមាតា និងនាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ ព្រះវស្សា ។ លុះឮពាក្យព្យាករណ៍ហើយ មានចិត្តរីករាយយ៉ាងខ្លាំងដោយត្រិះរិះថា បើដូច្នេះ អញនឹងជ្រើសរើសរកពុទ្ធការកធមិទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។

កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំដែលពោធិសត្វទាំងឡាយ អំពីបូរាណធ្លាប់សន្សំមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទានធ្វើនូវទានបារមីជាដំបូងនេះ ឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះចាក់មិនឱ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណាអ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឱ្យទាន កុំឱ្យសេសសល់ ឱ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។ ពុទ្ធធមិទាំង

ឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរក ពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាំងពោធិញ្ញាណឱ្យសម្រេច ។

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកឯងចូរសមាទានធ្វើ នូវសីលបារមីទី ២ នេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី (កាលឃើញ) រោមកន្ទុយ ចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោល ឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឱ្យដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាំងពោធិញ្ញាណឱ្យ សម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្ម បារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបូរាណ ធ្លាប់សេព ធ្លាប់ អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរ សមាទានធ្វើនេក្ខម្មបារមីទី ៣ នេះឱ្យមាំមួន បើអ្នកចង់លុះនូវ

ពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរ ឱ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច (ចាកគុកនោះ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរក នេក្ខម្មៈដើម្បីរួចចាកភព យ៉ាងនោះដែរ ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរក ពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះ ឱ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរ ជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះឱ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈ ជាស្ដេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឱ្យមាំមួន ក្នុងភពទាំងពួងយ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត)

អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះឱ្យមាំមួន អ្នកកុំមានចិត្ត បែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខាន ឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់ អាននិងការមើលងាយ របស់ជនពួកទាំងពួង យ៉ាងនោះដែរ លុះដល់ នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធមិទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធមិដទៃទៀត ដែលជាធមិញុំាងពោធិញ្ញាណឱ្យ សម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញ សច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទានធ្វើនូវសច្ចបារមីទី ៧ នេះឱ្យមាំមួន កុំមានពាក្យបែក ជាពីរ ក្នុងសច្ចបារមីនោះ នឹងបានសម្រេចនូវ សម្ពោធិញ្ញាណមិនខាន ឡើយ ។ ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។

អ្នកកុំឃ្លាតចាកវិថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធមិទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធមិដទៃទៀត ដែលជាធមិញុំាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះឱ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មឥតកំរើក តាំងនៅស៊ុប មិនរញ្ជួយ ដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកំរើកក្នុងអធិដ្ឋានបារមី សព្វកាលយ៉ាងនោះដែរ លុះបានដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធមិទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើស រើសរកពុទ្ធធមិដទៃទៀត ដែលជាធមិញុំាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញមេត្តា-

បារមីទី ៩ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឱ្យមាំមួន អ្នកចូរកុំឱ្យមានបុគ្គលដទៃទេស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតាទឹករមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អទាំងអាក្រក់ រមែងកំចាត់បង់នូវធូលីនិងមន្ទិល យ៉ាងណា ។ អ្នកចូរចំរើនមេត្តាឱ្យស្មើចំពោះមិត្រនិងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

ពុទ្ធធមិទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើស រើសរកពុទ្ធធមិដទៃទៀត ដែលជាធមិញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខា-បារមីទី ១០ ដែលពោធិសត្វទាំងឡាយ អំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះឱ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដីតែងព្រងើយកន្តើយចំពោះវត្ថុមិន ស្អាតក្តី

ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធនិងសេចក្តីត្រេកអរចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឱ្យដូចជាជញ្ជីង ចំពោះសុខនិងទុក្ខ សព្វកាលយ៉ាងនោះដែរ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខាន ។

ធម៌ទាំងឡាយ ជាគ្រឿងញុំាងពោធិញ្ញាណឱ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណេះ ពុទ្ធការកធម៌ដទៃក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះ ឱ្យមាំមួនចុះ ។ កាលតថាគត ពិចារណានូវបារមីធម៌ទាំងនេះ ដោយសភាវៈសរសលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជៈនៃធម៌ ។ ផែនដីកំរើកបន្លឺឡើង ដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬចក្រយន្តប្រេង ត្រូវគេគាបហើយ (រមែងវិលញ័រ) យ៉ាងណា ផែនដីក៏ញាប់ញ័រយ៉ាងនោះដែរ ។ បរិស័ទរបស់ព្រះពុទ្ធមានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រដេកជ្រប់លើផែនដី ក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់និងក្អមជាច្រើនរយក៏ទង្គិចគ្នាបែកខ្ទិចខ្ទីអស់ក្នុងទីនោះ ។ ពួកមហាជនមានចិត្តរន្ធត់តក់

ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ (ហើយទូលសួរថា) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អឬហេតុអាក្រក់ដូចម្ដេច នឹងមានដល់មនុស្សលោក លោកទាំងមូល ត្រូវសេចក្ដីអន្ដរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដីអន្ដរាយនោះចេញ ។ គ្រានោះព្រះមហាមុនីទីបង្ករ ទ្រង់ញុំាងមហាជនទាំងនោះ ឱ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ត្បិតតថាគតបាន ព្យាករណ៍ក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក (ក្នុងកាលជាអនាគត) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបូរាណ ធ្លាប់សេពមក ។ កាលសុមេធបណ្ឌិត ពិចារណាធម៌គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោកព្រមទាំងទេវលោកញាប់ញ័រ ។ ចិត្ត(នៃមហាជន) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគត ហើយក្រាបថ្វាយ

បង្គំម្តងទៀត ។ គ្រានោះ តថាគតសមាទាននូវពុទ្ធគុណ ធ្វើចិត្តឱ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ។ ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនោះ បាននូវសួស្តី (ពោលថា) តំណែងដ៏ធំ ដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបរវៀសចៀសចេញទៅ សេចក្តីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្តីអន្តរាយកុំបីមានដល់លោកឡើយ សូមលោកបានលុះ នូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កា ដោយពុទ្ធញ្ញាណយ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌល យ៉ាងណា បពិត្រតាបសមាន

ព្យាយាមធំ លោកចូរត្រាស់ដឹងទៀបគល់ពោធិមណ្ឌល នៃព្រះជិនស្រី យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្រ ឱ្យប្រព្រឹត្តទៅយ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញចូររុងរឿងក្នុង លោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកំដៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណាពួកលោកព្រមទាំង ទេវលោក ក៏រមែងប្រជុំក្នុងសំណាក់របស់លោក យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតានិងមនុស្សទាំងនោះ ស្ញើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ។

ចប់ សុមេធកថា

# ទានបារមិតា

## អកិត្តិចរិយា ទី ១

(១) អំពើណា ដែលតថាគតបានប្រព្រឹត្តហើយ ក្នុងរវាងនេះ អស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប អំពើទាំងអស់នោះ ជាគ្រឿងញ៉ាំងពោធិញ្ញាណឱ្យសម្រេច ។ តថាគតលើកទុកនូវអំពើ ដែលតថាគតបានប្រព្រឹត្តក្នុងភពតូចនិងភពធំ ក្នុងកប្បដែលកន្លងទៅហើយ នឹងសំដែងតែអំពើដែលតថាគត បានប្រព្រឹត្តហើយក្នុងភទ្ទកប្បនេះ អ្នកចូរស្តាប់តថាគតចុះ ។ កាលដែលតថាគតជាតាបស ឈ្មោះអកិត្តិ ចូលទៅនៅក្នុងព្រៃធំនិងព្រៃតូច ជាព្រៃស្ងាត់សូន្យឈឹង ។ កាលនោះ ព្រះឥន្ទ្រអ្នកគ្របសង្កត់ទេវលោក ទ្រង់ក្តៅដោយតេជៈ គឺតបៈធម៌នៃតថាគត ក៏ក្លែងភេទជាព្រាហ្មណ៍ ចូលមករកតថាគតដើម្បីសូមភិក្ខា ។ តថាគតឃើញព្រាហ្មណ៍ ឈរទៀបទ្វារបណ្ណសាលារបស់តថាគត ក៏ឱ្យស្លឹកដង្កៀបក្តាមទាំងអស់ដែលតថាគតនាំមកពីព្រៃ ជាស្លឹកមិនមានប្រេង មិនមានរសប្រៃ ព្រមទាំងភាជន៍ ។

លុះតថាគត ឱ្យស្លឹកដង្កៀបក្ដាម ដល់ព្រាហ្មណ៍ហើយ ក៏ផ្កាប់ភាជន៍ លះបង់នូវការស្វែងរកទៀត ហើយចូលទៅក្នុងបណ្ណសាលា ។ ក្នុងថ្ងៃទី ២ និងថ្ងៃទី ៣ ព្រាហ្មណ៍ចូលមកក្នុងសំណាក់តថាគតទៀត តែតថាគតមិនញាប់ញ័រ មិនជាប់ចំពាក់ បានឱ្យយ៉ាងនុ៎ះទៀត សរីរៈរបស់តថាគត មិនមានប្លែកភេទ ព្រោះហេតុទាននោះ តថាគត ញុំាងកាលឱ្យប្រព្រឹតកន្លងទៅអស់ថ្ងៃនោះ ព្រោះសេចក្ដីត្រេកអរ ដោយសុខដែលកើតអំពីបីតិ ។ បើតថាគតបានទក្ខិណេយ្យបុគ្គលដ៏ប្រសើរ អស់មួយខែឬពីរខែទៀត តថាគតមិនញាប់ញ័រមិនរួញរា នឹងឱ្យទានដ៏ឧត្ដមឡើយ ។ តថាគតកាលឱ្យទាន ដល់ឥន្ទព្រាហ្មណ៍នោះ ទាំងបានប្រព្រឹត្តនូវអំពើទាំងឡាយនោះ មិនប្រាថ្នានូវយសនិងលាភទេ តថាគតប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណតែម្យ៉ាង ។

ចប់ អកិត្តិចរិយា ទី ១ ។

## សង្ខព្រាហ្មណចរិយា ទី ២

(២) មានចរិយាដទៃទៀត កាលដែលតថាគតកើតជាព្រាហ្មណ៍ ឈ្មោះសង្ខៈ មានប្រាថ្នាដើម្បីឆ្លងមហាសមុទ្រសំដៅទៅកាន់កំពង់ (តម្ពលិត្តិ) ។ កាលនោះ តថាគតបានឃើញព្រះបច្ចេកពុទ្ធដែលត្រាស់ដឹងឯង ទ្រង់ឈ្មោះមារ កំពុងនិមន្តទៅកាន់ផ្លូវលំបាក លើផែនដីរងិបរងុបដ៏ក្តៅ ត្រង់ផ្លូវជួបគ្នានោះ ។ លុះតថាគត ឃើញព្រះបច្ចេកពុទ្ធ ត្រង់ផ្លូវជួបគ្នានោះ ក៏គិតនូវសេចក្តីនេះថា ស្រែបុណ្យនេះរមែងសម្រេចដល់សត្វអ្នកប្រាថ្នានូវបុណ្យ ប្រៀបដូចបុរសអ្នកភ្ជួរឃើញស្រែឬសួនច្បារធំ មិនព្រោះពូជក្នុងស្រែនោះទេ បុរសនោះឈ្មោះថា ជាអ្នកមិនត្រូវការដោយស្រូវ យ៉ាងណាមិញ ។ តថាគតជាអ្នកចង់បានបុណ្យ បើឃើញស្រែបុណ្យដ៏ប្រសើរថ្លៃថ្លាហើយ មិនធ្វើសក្ការទេ តថាគតឈ្មោះថា ជាអ្នកមិនត្រូវការដោយបុណ្យយ៉ាងនោះឯង ។ម្យ៉ាងទៀត ប្រៀបដូចអាមាត្យ មានប្រាថ្នាជាធំក្នុងក្រសួងត្រា (ហើយបណ្តេញ) ពួកជនក្នុងវាំងរបស់ស្តេច មិនឱ្យទ្រព្យនិងស្រូវដល់ជនទាំងនោះ អាមាត្យនោះរមែងសាបសូន្យចាកត្រាយ៉ាងណាមិញ តថាគតជាអ្នកប្រាថ្នាបុណ្យ បានឃើញទក្ខិណេយ្យ-

បុគ្គលដ៏ធំទូលាយ ហើយមិនឱ្យទានដល់ ទក្ខិណេយ្យបុគ្គលនោះ តថាគតរមែងសាបសូន្យចាកបុណ្យ ក៏យ៉ាងនោះដែរ ។ តថាគតលុះគិតឃើញយ៉ាងនេះហើយ ក៏ដោះស្បែកជើងថ្វាយបង្គំព្រះបាទានៃព្រះបច្ចេកពុទ្ធនោះ រួចប្រគេនឆត្រនិងស្បែកជើង ។ ហេតុនោះបានជាតថាគត ចំរើនដោយសេចក្ដីសុខ ដល់នូវសេចក្ដីសុខ ដោយរយគុណ ម្យ៉ាងទៀត តថាគតកាលបំពេញទាន ក៏បានឱ្យទានដល់ព្រះបច្ចេកពុទ្ធយ៉ាងនេះឯង ។

ចប់ សង្ខព្រាហ្មណចរិយា ទី ២

## កុរុធម្មចរិយា ទី ៣

(៣) ចរិយាដទៃទៀត កាលតថាគតជាស្ដេច ឈ្មោះធនញ្ជ័យ នៅក្នុងឥន្ទបត្តបុរីដ៏ឧត្ដម ប្រកបដោយកុសលធម៌ ១០ ។ ព្រាហ្មណ៍ទាំងឡាយ នៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឱ្យបានទ្រព្យ ដែលគេសន្មតថា ជាសត្វមង្គលដោយពាក្យថា ជនបទ(នៃយើងខ្ញុំព្រះអង្គ) មិនមានភ្លៀងទុរ្ភិក្ស

អត់ឃ្លានខ្លាំងណាស់ សូមព្រះអង្គប្រទានដំរីប្រសើរ ដែលមានសម្បុរខៀវឈ្មោះអញ្ជ័ន ។ បើស្ទូមមកដល់ហើយ តថាគតមិនគួរប្រកែកការសមាទានរបស់តថាគត កុំបែកធ្លាយឡើយដូច្នេះ តថាគតនឹងឱ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ ច្រួចទឹកកុណ្ឌីជាវិការនៃកែវ លើដៃព្រាហ្មណ៍ ហើយឱ្យដំរីដល់ព្រាហ្មណ៍ កាលតថាគតឱ្យដំរីដល់ពួក ព្រាហ្មណ៍ហើយ មានពួកអាមាត្យក្រាបទូលពាក្យនេះថា ហេតុដូចម្តេច បានជាព្រះអង្គ ប្រទានដំរីដ៏ប្រសើររបស់ព្រះអង្គដែលជាដំរីនាំឱ្យបានទ្រព្យប្រកបដោយមង្គល ជាដំរីឧត្តមក្នុងសង្គ្រាមជ័យដល់ពួកស្ទូម កាលបើព្រះអង្គប្រទានដំរីដ៏ប្រសើរ ដល់ពួកស្ទូមនោះហើយ ព្រះអង្គសោយរាជ្យធ្វើអ្វី? ។ តថាគតតបថា តថាគតអាចនឹងឱ្យរាជ្យទាំងអស់ របស់តថាគត ដល់ស្ទូមក៏បាន ឬនឹងឱ្យសរីរៈរបស់ខ្លួន ដល់ពួកស្ទូមក៏បាន ដ្បិតសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឱ្យដំរីដ៏ប្រសើរ ។

ចប់ កុរុធម្មចរិយា ទី ៣ ។

# មហាសុទស្សនចរិយា ទី ៤

(៤) កាលតថាគត ជាក្សត្រចក្រពត្តិ ឈ្មោះមហាសុទស្សនៈ មានពលច្រើន នៅក្នុងនគរកុសាវតី ។ ក្នុងនគរនោះ តថាគតបានឱ្យគេឃោសនា ក្នុងមួយថ្ងៃ ៣ ដង ក្នុងទីនោះៗថា អ្នកណាប្រាថ្នាចង់បានអ្វី ចូរឱ្យនូវទ្រព្យអ្វីដល់អ្នកណា ។ អ្នកណាឃ្លាន អ្នកណាស្រេក អ្នកណា(ប្រាថ្នា) នូវកម្រងផ្កា អ្នកណា(ប្រាថ្នា)នូវគ្រឿងលាប អ្នកណា អាក្រាតនឹងស្លៀកដណ្តប់នូវសំពត់ទាំងឡាយ ដែលជ្រលក់ដោយពណ៌ផ្សេងៗ អ្នកណាយកឆត្រ(ដើម្បីបាំង)ក្នុងផ្លូវ អ្នកណាយកស្បែកជើងដ៏ទន់ល្អ (ដើម្បីពាក់ក្នុងផ្លូវ) ។ តថាគតឱ្យគេ ឃោសនាក្នុងវេលាព្រឹក (ថ្ងៃត្រង់) ល្ងាច ក្នុងទីនោះ ៗ ដូចបាន ពោលហើយក្នុងខាងលើ ទាននោះតថាគត មិនមែនចាត់ចែងតែក្នុងទី ១០ កន្លែង មិនមែនចាត់ចែងតែក្នុងទី មួយរយកន្លែងទេ ។ ទ្រព្យដែលតថាគតចាត់ចែងចំពោះស្មូម ក្នុងទីច្រើនរយកន្លែង សំរាប់ពួកវណិព្វកៈ ដែលមកក្នុងវេលាថ្ងៃ ឬមកក្នុងវេលាយប់ ។ ពួកស្មូមលុះតែបាន

ភោគៈ គួរតាមសេចក្តីប្រាថ្នា ពេញក្នុងដៃហើយ ទើបបានដើរចេញទៅ តថាគតបានឱ្យមហាទានបែបនេះ ដរាបដល់អស់ជីវិត ។ តថាគតមិនឱ្យទ្រព្យ ដែលមិនជាទីគាប់ចិត្តទេ ម្យ៉ាងទៀត តថាគតមិនមែន ជាអ្នកមិនសន្សំទ្រព្យទុកទេ ដូចបុរសកើតរោគក្តៅក្រហាយ ចង់ជារោគ ញុំាងពេទ្យឱ្យស្កប់ស្កល់ដោយទ្រព្យ រមែងរួចចាករោគយ៉ាងណាមិញ តថាគតកាលដឹងច្បាស់ថា (ការឱ្យទានជាឧបាយ) ដើម្បីបំពេញអធ្យាស្រ័យរបស់សត្វ ដោយមិនមានសេសសល់ តថាគតឱ្យទានចំពោះស្មូមដើម្បីបំពេញ ចិត្តស្មូមដែលខ្វះកន្លះ តថាគតជាអ្នកមិនមានអាល័យ មិនមានសេចក្តីប៉ុនប៉ង (ចំពោះផលនៃទាននោះទេ តថាគតឱ្យទាន) ដើម្បីបានត្រាស់ ដឹងនូវសម្ពោធិញ្ញាណយ៉ាងនេះឯង ។

ចប់ មហាសុទស្សនចរិយា ទី ៤ ។

# មហាគោវិន្ទចរិយា ទី ៥

(៥) ចរិយាដទៃទៀត កាលតថាគតកើតជាមហាគោវិន្ទ-ព្រាហ្មណ៍ បានជាបុរោហិតនៃស្តេច ៧ អង្គ ជាបុរោហិតដែលមនុស្សនឹងទេវតាបូជាហើយ ។ សួយសារអាករណា ដែលកើតដល់តថាគតក្នុងរាជ្យនៃស្តេច ៧ អង្គ ក្នុងកាលនោះ តថាគតបានឱ្យនូវមហាទានជាទានមិនកំរើក ដូចជាសាគរ ដោយសួយសារអាករនោះ ។ ទ្រព្យនិងស្រូវ មិនមែនជាទីស្អប់ខ្ពើមរបស់តថាគតទេ ទាំងការសន្សំទ្រព្យនៃតថាគត មិនមែនជាមិនមានទេ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឱ្យទ្រព្យដ៏ប្រសើរ ។

ចប់ មហាគោវិន្ទចរិយា ទី ៥ ។

# នេមិរាជចរិយា ទី ៦

(៦) ចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចធំឈ្មោះនេមិ ជាបណ្ឌិត អ្នកត្រូវការដោយកុសល នៅក្នុងក្រុងដ៏ប្រសើរឈ្មោះមិថិលា ។ កាលនោះតថាគតបានឱ្យគេ ស្ថាបនាសាលាបួនខ្នង មានមុខ ៤ ហើយញ៉ាំងទានឱ្យប្រព្រឹត្តទៅដល់ពួកម្រឹគបក្សីនិងមនុស្សជាដើម ក្នុងសាលានោះ ។ តថាគតបានធ្វើនូវសំពត់សំរាប់ស្លៀកដណ្តប់ ទីដេក បាយ ទឹកនិងភោជន ឱ្យជារបស់ប្រព្រឹត្តទៅមិនដាច់ ហើយញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅ ។ សេវកាមាត្យ ចូលទៅរកចៅហ្វាយនាយ ព្រោះហេតុចង់បានទ្រព្យ ហើយស្វែងរកហេតុ ដែលគួររីករាយ ដោយកាយឬដោយវាចាចិត្ត (ផ្គាប់ចិត្តចៅហ្វាយនាយ) យ៉ាងណា ។ តថាគតនឹងស្វែងរកនូវពូជនៃពោធិញ្ញាណក្នុងភពទាំងពួង ញ៉ាំងសត្វឱ្យស្កប់ស្កល់ដោយទាន ហើយប្រាថ្នានូវពោធិញ្ញាណដ៏ឧត្តម យ៉ាងនោះឯង ។

ចប់ នេមិរាជចរិយា ទី ៦ ។

# ចន្ទកុមារចរិយា ទី ៧

(៧) មានចរិយាដទៃទៀត កាលដែលតថាគតជាឱរស ឈ្មោះ ចន្ទកុមារ របស់ស្តេចព្រះនាមឯករាជ នៅក្នុងក្រុងបុប្ផវតី ។ កាលនោះ តថាគតរួចអំពីការដែលគេត្រូវសម្លាប់ ចេញផុតពីទីយ័ញ្ញនោះហើយ ក៏កើតសេចក្តីសង្វេគ បានញុំាងមហាទាន ឱ្យប្រព្រឹត្តទៅ ។ តថាគតបើ មិនទាន់បានឱ្យទេយ្យធម៌ ចំពោះទក្ខិណេយ្យបុគ្គលទេ តថាគតក៏មិន ផឹក មិនទំពាស៊ី មិនបរិភោគភោជនអស់ចំនួន ៥ ឬ ៦ រាត្រី ។ ពាណិជ ធ្វើការសន្សំទ្រព្យ (បើដឹងថា) ទីណាមានលាភច្រើន ក៏នាំភណ្ឌទៅក្នុងទីនោះ យ៉ាងណា ។ វត្ថុដែលត្រូវបរិភោគខ្លួនឯង បើឱ្យដល់បដិគ្គាហកៈដទៃ ជាវត្ថុមានផលច្រើន ហេតុនោះត្រូវតែឱ្យដល់បុគ្គលដទៃវិញ នឹងមានផល ១០០ ភាគ ក៏យ៉ាងនោះដែរ ។ តថាគត ដឹងនូវអំណាចនៃ ហេតុនុ៎ះហើយ ទើបឱ្យទានក្នុងភពតូចនិងភពធំ មិនគេចចេញចាកទាន ដើម្បីបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ ។

ចប់ ចន្ទកុមារចរិយា ទី ៧ ។

# សិវិរាជចរិយា ទី ៨

(៨) កាលតថាគត ជាក្សត្រឈ្មោះសិវិ សោយរាជ្យក្នុងនគរអរិដ្ឋៈ អង្គុយក្នុងប្រាសាទដ៏ប្រសើរ តថាគតគិតយ៉ាងនេះថា ទានណាមួយ ជារបស់មនុស្ស ទាននោះគឺអញមិនដែលឱ្យហើយ មិនមានឡើយ បើមានយាចកណាមក សូមភ្នែកអញ អញនឹងមិនញាប់ញ័រ ត្រូវតែឱ្យ (ដល់យាចកនោះ) សក្កៈជាធំជាងពួកទេវតា បានដឹងនូវសេចក្តីត្រិះរិះ របស់តថាគត អង្គុយនៅក្នុងទេវបរិស័ទ ក៏ពោលនូវពាក្យនេះថា ស្តេចសិវិមានឫទ្ធិច្រើន គង់ក្នុងប្រាសាទដ៏ប្រសើរ កំពុងពិចារណានូវទានផ្សេង ៗ (ដែលខ្លួនឱ្យហើយ) ស្តេចនោះមិនឃើញនូវវត្ថុ ដែលខ្លួនមិនធ្លាប់ឱ្យសោះឡើយ ។ ការណ៍នុ៎ះពិតឬមិនពិតអេះ បើដូច្នេះ អញនឹងល្បងស្តេចនោះមើល អ្នកទាំងឡាយចូររង់ចាំមួយរំពេច ទំរាំយើងបានដឹងនូវរាជហឫទ័យ នៃស្តេចនោះ (ព្រះឥន្ទ្រក៏ក្លែងខ្លួនជាព្រាហ្មណ៍) មានសក់ស្កូវ មានខ្លួនជ្រួញជ្រីវ

ទូរន់ទូរាដោយជរា ព្រមទាំងមានសម្បុរអាក្រក់ ដើរញញាក់ញញ័រ ចូលទៅរកព្រះរាជា ។ គ្រានោះ ព្រាហ្មណ៍នោះផ្គងដៃឆ្វេងនិងដៃស្តាំ ហើយធ្វើអញ្ជលីលើសិរ្ស ពោលពាក្យនេះថា បពិត្រធម្មិកមហារាជ ជាអ្នកញុំាងដែនឱ្យចំរើន ខ្ញុំព្រះអង្គ សូមអង្វរព្រះអង្គ កិត្តិសព្ទរបស់ ព្រះអង្គ ថាត្រេកអរក្នុងទាន ល្បីទូទ័រទៅក្នុង ទេវលោកនិង មនុស្សលោក ។ ភ្នែកទាំងពីរនៃទូលបង្គំ ត្រូវងងឹតបៀតបៀន ហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រមួយដល់ទូលព្រះបង្គំ ចំណែក ព្រះអង្គ សូមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយព្រះនេត្រម្ខាងចុះ ។ តថាគតឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏រីករាយមានចិត្តសង្វេគ ធ្វើ អញ្ជលីមានសេចក្តីត្រេកអរ ហើយពោលថា ខ្ញុំទើបនឹងគិតឃើញ អម្បាញ់មិញនេះ ហើយចុះអំពីប្រាសាទមកក្នុងទីនេះ អ្នកទំនង ជាដឹងចិត្តខ្ញុំ ទើបមកសូមភ្នែកខ្ញុំ ឱហ្ន៎ ! សេចក្តីប្រាថ្នាក្នុងចិត្តនៃខ្ញុំ សម្រេចហើយ សេចក្តីត្រិះរិះនៃខ្ញុំពេញហើយ ទានដ៏ប្រសើរដែលខ្ញុំ មិនធ្លាប់ឱ្យ ខ្ញុំនឹងឱ្យដល់ស្មូមក្នុងថ្ងៃនេះ ។ ម្នាលពេទ្យឈ្មោះសិវកៈ

អ្នកចូលមក ចូរក្រោកឡើង កុំបង្អង់ឱ្យយឺតយូរឡើយ កុំញាប់ញ័រចូរឆ្កៀលភ្នែកទាំងពីរ (របស់អញ) ហើយឱ្យដល់ស្នូម ។ លំដាប់នោះពេទ្យសិវកៈនោះ ដែលតថាគតដាស់តឿនហើយ ក៏ធ្វើតាមពាក្យតថាគត បានខ្វេះឆ្កៀល(ភ្នែកតថាគត) ហើយប្រគល់ឱ្យដល់ស្នូមដូចជាឱ្យសាច់ត្នោត ។ ក្នុងកាលមុនឱ្យក្តី កំពុងឱ្យក្តី ឱ្យរួចហើយក្តី ចិត្តរបស់តថាគត ឥតមានការរាយមាយឡើយ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។ ភ្នែកទាំងពីរ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនសោតទៀត ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់ របស់តថាគត ព្រោះហេតុនោះបានជាតថាគតឱ្យចក្ខុ ។

ចប់ សិវិរាជចរិយា ទី ៨ ។

# ទេសន្តរចរិយា ទី ៩

(៩) ព្រះនាងផុស្សតី ខត្តិយកញ្ញា ជាព្រះជននីរបស់តថាគត ព្រះនាងផុស្សតីនោះ ជាព្រះមហេសីនៃសក្កទេវរាជ ក្នុងអតីតជាតិទាំងឡាយ ។ ព្រះឥន្ទ្រទ្រង់ជ្រាប នូវការអស់ទៅនៃអាយុរបស់ព្រះនាងហើយ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលនាងដ៏ចំរើន យើងនឹងឱ្យពរ ១០ ប្រការ ដល់នាងបើនាងប្រាថ្នានូវពរណា ចូរទទួលយកនូវពរនោះចុះ ។ ព្រះនាងទេវីនោះ កាលបើព្រះឥន្ទ្រ ពោលយ៉ាងនេះហើយ ក៏ពោលពាក្យនេះ តបនឹងព្រះឥន្ទ្រវិញថា ខ្ញុំមានទោសកំហុសដូចម្តេច ខ្ញុំជាទីស្អប់របស់ព្រះអង្គយ៉ាងណាទៅ បានជាព្រះអង្គញុំាងខ្ញុំឱ្យឃ្លាត ចាករមណីយដ្ឋាន ដូចជាខ្យល់បក់បោករំលំនូវរុក្ខជាតិដែលដុះលើផែនដី ដូច្នោះ ។ សក្កទេវរាជនោះ លុះឮព្រះនាងផុស្សតីពោលយ៉ាងនេះហើយ ក៏ត្រាស់ពាក្យនេះ តបនឹងព្រះនាងវិញថា អំពើដ៏លាមក នាងមិនបានធ្វើទេ នាងមិនមែនជាទីស្អប់របស់យើងទេ ។ អាយុរបស់នាងត្រឹមតែប៉ុណ្ណេះ កាលជាទីច្យុតនឹងមាន (ដល់នាង) ចូរនាងទទួលយកពរដ៏ប្រសើរឧត្តម ១០ ប្រការ ដែលយើងឱ្យនេះចុះ ។

ព្រះនាងផុស្សតីនោះ បានទទួលពរដែលសក្កទេវរាជឱ្យហើយ ក៏មានព្រះហឫទ័យត្រេកអររីករាយ ធ្វើតថាគតឱ្យនៅខាងក្នុង (ពរទាំងនោះ) ហើយទទួលយកពរទាំង ១០ ប្រការ ។ ព្រះនាងផុស្សតីនោះលុះច្យុតចាកឋានទេវលោកនោះហើយ មកកើតក្នុងត្រកូលក្សត្រ ហើយមកភប់ប្រសព្វនឹង សញ្ជយរាជកុមារ ក្នុងជេតុត្តរនគរ ។ កាលនោះតថាគតចុះមកកាន់ផ្ទៃ នៃនាងផុស្សតីជារាជមាតា ដែលជាទីស្រឡាញ់ ក្នុងកាលនោះ ដោយតេជានុភាពរបស់តថាគត មាតានៃតថាគត ក៏ត្រេកអរក្នុងទានសព្វ ៗ កាល ។ ព្រះនាងផុស្សតីនោះទ្រង់បរិច្ចាគទាន ដល់ពួកជនអ្នកឥតទ្រព្យ ពួកជនឈឺជានិច្ច ពួកជនចាស់ជរា ពួកយាចក ពួកអ្នកដំណើរ និងពួកសមណព្រាហ្មណ៍ដែលមានអាសវៈអស់ហើយ មិនមានកិលេស ជាគ្រឿងកង្វល់ ។ កាលព្រះនាងផុស្សតីទេវីនោះ ទ្រង់គភ៌គ្រប់ ១០ ខែហើយ ព្រះបាទសញ្ជយមហារាជ ទ្រង់នាំព្រះនាងទៅធ្វើប្រទក្សិណបុរី ព្រះនាងប្រសូតតថាគត ត្រង់កណ្តាលថ្នល់នៃអ្នកជំនួញ ។ ឈ្មោះរបស់តថាគត មិនមែនជាប់មកអំពីមាតា មិនមែនជាប់មកអំពីបិតាទេ គឺ

ព្រោះតែតថាគត កើតត្រង់កណ្ដាលផ្លូវអ្នកជំនួញ ហេតុនោះបានជាឈ្មោះថាវេស្សន្តរ ។ កាលណា តថាគតជាទារក មានអាយុ៨ឆ្នាំអំពីកំណើត ក្នុងកាលនោះ តថាគតអង្គុយក្នុងប្រាសាទ ត្រិះរិះដើម្បីឱ្យនូវអជ្ឈត្តិកទានថា បើអ្នកណាមកសូមតថាគត តថាគតគប្បីឱ្យបេះដូង ឱ្យភ្នែក ឱ្យសាច់និងឈាម ឬក៏គេញ៉ាំងតថាគតឱ្យដឹងឮថា (អ្នកចូរធ្វើជាទាសៈរបស់ខ្ញុំ) តថាគតនឹងព្រមប្រគល់កាយ (ដល់អ្នកនោះ) ។ កាលតថាគត កំពុងគិតនូវភាពដែលមិនញាប់ញ័រ ដែលមិនរួញរា មហាប្រថពីមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងទីនោះ ។ តថាគតឡើងជិះដំរីឈ្មោះបច្ច័យ ចូលទៅ (កាន់សាលាទាន) ដើម្បីឱ្យទានក្នុងថ្ងៃឧបោសថ ខែពេញបូណ៌មីទី ១៥ ក្នុងកន្លះខែជាលំដាប់ ។ ព្រាហ្មណ៍ទាំងឡាយ ដែលនៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឱ្យបានទ្រព្យដែលគេសន្មតជាសត្វមង្គលថា ជនបទ (របស់យើងខ្ញុំព្រះអង្គ) មិនមានភ្លៀង ទុរ្ភិក្ខអត់ឃ្លានខ្លាំង សូមព្រះអង្គព្រះរាជទានដំរីប្រសើរ មានអវយវៈសសុទ្ធជាដំរីឧត្តម ។ ព្រាហ្មណ៍ទាំងឡាយ

សូមដំរីណា ចំពោះតថាគត តថាគតឱ្យដំរីនោះ ឥតញាប់ញ័រឡើយ តថាគតមិនលាក់លៀមនូវ ទេយ្យធម៌ដែលមាន ព្រោះចិត្តរបស់តថាគតត្រេកអរក្នុងទាន ។ កាលបើយាចកមកដល់ហើយ ការប្រកែកក៏មិនសមគួរដល់តថាគត ការសមាទានរបស់តថាគត កុំបីបែកធ្លាយឡើយ ដូច្នេះ តថាគតនឹងឱ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ រួចច្រូចទឹកក្នុងកុណ្ឌីជាវិការនៃកែវ ដាក់លើដៃព្រាហ្មណ៍ ហើយឱ្យដំរីដល់ព្រាហ្មណ៍ ។ កាលតថាគតឱ្យដំរីដ៏ឧត្តមសសុទ្ធដទៃទៀត ក្នុងកាលនោះ មហាប្រថពី ដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ក៏ញាប់ញ័រ ។ ព្រោះតែការឱ្យនូវដំរីនោះជាហេតុនាំឱ្យពួកអ្នកដែនសិវិ ខឹងខ្លាំងក៏មកប្រជុំគ្នា ហើយបណ្តេញតថាគតចាកដែនរបស់ខ្លួនដោយពាក្យថា សូមព្រះអង្គទៅនៅវង្កតបពិតទៅ ។ កាលពួកអ្នកដែនសិវិនោះ បណ្តេញតថាគតឱ្យចេញចាកដែន ចិត្តរបស់តថាគតមិនញាប់ញ័រ មិនតក់ស្លុតទេ តថាគតបានសូមពរមួយដ៏ប្រសើរ នឹងជនទាំងនោះ ដើម្បីញ៉ាំងមហាទានឱ្យប្រព្រឹត្តទៅ ។ ពួកអ្នកដែនសិវិទាំងអស់ ដែលតថាគតសូមពរហើយ

ក៏ឱ្យនូវពរមួយដ៏ប្រសើរ ដល់តថាគត ៗញ៉ាំងគេឱ្យដឹងឮដោយស្គរ មានត្រចៀកហើយឱ្យមហាទាន ។ គ្រានោះ សម្លេងកោលាហល ដែលនាំឱ្យភ័យធំ ក៏ប្រព្រឹត្តទៅក្នុងរោងទានទុំះថា (ពួកអ្នកដែនសិវិ) បណ្តេញព្រះបាទវេស្សន្តរនេះ ព្រោះតែទាន ឥឡូវព្រះបាទវេស្សន្តរនេះ នៅតែឱ្យទានទៀត ។ កាលនោះ តថាគតឱ្យដំរី សេះ រថ ខ្ញុំស្រី ខ្ញុំប្រុស មេគោនិងទ្រព្យ លុះឱ្យមហាទានហើយ ក៏ចេញអំពីនគរ លុះតថាគត ចេញចាកនគរហើយ ក៏ងាកមើលទៅព្រះនគរវិញ កាលនោះ មហាប្រថពីដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ តថាគតឱ្យនូវរថដែលទឹម ដោយសេះសន្ធព ៤ ហើយឋិតនៅក្នុងផ្លូវធំ ៤ ជាបុគ្គលតែម្នាក់ឯង មិនមានបុគ្គលជាគំរប់ពីរ និយាយនូវពាក្យនេះនឹងនាងមទ្រីទេវីថា ម្នាលនាងមទ្រី នាងចូរពកណ្ហាជិនាចុះ ព្រោះកណ្ហា ជិនាជាប្អូននេះស្រាល បងនឹងពជាលីកុមារ ព្រោះជាលីកុមារជាបងធ្ងន់ ។ ព្រះនាងមទ្រីទេវីពកណ្ហាជិនាដូចជាផ្កាឈូកស តថាគតពក្យត្រជាលី ដូចជារូបភាពជាវិការៈនៃមាស ។ ខត្តិយជនទាំង ៤ អង្គ ធ្លាប់ចំរើន ដោយសេចក្តីសុខ មាន

ជាតិខ្ពង់ខ្ពស់ កាលស្ដេចទៅក្នុងផ្លូវ មិនរាបស្មើខ្លះ រាបស្មើខ្លះ (ដោយគិតថា) យើងនឹងទៅកាន់វង្កតបព៌ត ។ បើមនុស្ស ណាមួយដើរមកក្នុងផ្លូវបណ្ដោយគ្នា ឬផ្លូវច្បបគ្នា យើងនឹងសាកសួរផ្លូវនឹងមនុស្សទាំងឡាយនោះថា វង្កតបព៌តនៅក្នុងទីណា ។ មនុស្សទាំងនោះ ឃើញយើងក្នុងទីនោះ នឹងប្រាប់ (នូវផ្លូវដែលទៅ) កាន់ភ្នំដោយសេចក្ដីករុណា មនុស្សទាំងនោះ ដឹងនូវទុក្ខ (របស់យើងនឹងប្រាប់ថា) វង្កតបព៌ត នៅក្នុងទីឆ្ងាយអំពីទីនេះ ។ បើទារកទាំងពីរឃើញឈើមាន ផ្លែក្នុងព្រៃធំ ព្រោះហេតុនៃផ្លែឈើទាំងនោះទារកទាំងពីរនឹងយំទារ ។ ដើមឈើធំខ្ពស់ទាំងឡាយ ព្រោះឃើញទារកទាំងពីរយំ ក៏ទោរទន់ចូលមកជិត ទារកដោយខ្លួនឯង ។ នាងមទ្រីមានអវយវៈទាំងអស់ល្អ ឃើញនូវហេតុគួរអស្ចារ្យ ចំឡែកគួរព្រឺរោម ក៏ញុំាងសាធុការឱ្យប្រព្រឹត្តទៅថា ឱហ្ន៎! ហេតុអស្ចារ្យចំឡែក គួរព្រឺរោមកើតឡើងហើយ ក្នុងលោកនេះ ដោយតេជៈនៃព្រះវេស្សន្តរ ដើមឈើទាំងឡាយ ក៏ទោរទន់ចុះមកដោយខ្លួនឯង ។ ពួកទេវតាបានបង្រួញផ្លូវ ដោយសេចក្ដីអនុគ្រោះ ចំពោះទារក

ញ៉ាំងជនទាំងនោះ ឱ្យដល់ដែនចេតៈ ក្នុងថ្ងៃដែលខ្លួនចេញទៅ ។ កាលនោះ ស្តេចទាំងអស់ ៦០.០០០ អង្គ ដែលនៅក្នុងមាតុលនគរ ក៏ប្រណម្យអញ្ជលីទូញយំ ដើរចូលមកជិត ។ ក្សត្រទាំងបួនព្រះអង្គនោះ និយាយចរចាជាមួយ នឹងស្តេចចេតៈទាំងឡាយ នឹងពួកបុត្ររបស់ស្តេចចេតៈ ក្នុងទីនោះ ហើយលាចេញពីទីនោះទៅថា យើងនឹងទៅកាន់វង្កតបពិត ។ ព្រះឥន្ទ្រ ទ្រង់ហៅនូវវិស្សុកម្មទេវបុត្រ ដែលមានឫទ្ធិច្រើនមកប្រាប់ថា អ្នកចូរនិម្មិតអាស្រមនិងបណ្ណសាលាដ៏ល្អជាទីរីករាយ ថ្វាយព្រះបាទវេស្សន្តរ ព្រមទាំងភរិយានិងបុត្រ ។ វិស្សុកម្មទេវបុត្រ ដែលមានឫទ្ធិច្រើន លុះបានស្តាប់ពាក្យរបស់សក្កទេវរាជហើយ ក៏ចុះមកនិម្មិតអាស្រមនិងបណ្ណសាលាដ៏ល្អជាទីរីករាយ ។ ក្សត្រ ៤ ព្រះអង្គ បានចូលទៅកាន់ព្រៃធំ ដែលមិនមានសម្លេង មិនមានសេចក្តីរិករវរ ហើយ(និយាយគ្នាថា) យើងនឹងនៅក្នុងចន្លោះនៃភ្នំនោះ កាលនោះ តថាគត នាងមទ្រីទេវី កូនទាំងពីរ គឺជាលី និងកណ្ហាជិនា បានបន្ទោបង់នូវសេចក្តីសោក ដល់គ្នានឹងគ្នា ហើយនៅក្នុងអាស្រម កាលនោះ តថាគតរក្សាទារកក្នុងអាស្រមមិន

សូន្យស្ងាត់ នាងមទ្រីនោះ តែងនាំផ្លែឈើមកចិញ្ចឹមជនទាំង៣នាក់ ។ កាលតថាគត នៅក្នុងព្រៃធំ មានអ្នកដំណើរម្នាក់ ចូលមករកតថាគត សូមកូនទាំងពីរ នៃតថាគត គឺជាលីនិងកណ្ហាជិនា ។ កាលនោះ តថាគតកើតសេចក្ដីរីករាយ ព្រោះបានឃើញយាចកដើរចូលមក បានយកកូនទាំងពីរឱ្យដល់ព្រាហ្មណ៍ ។ កាលតថាគតបរិច្ចាគបុត្រទាំងពីររបស់ខ្លួន ដល់ជូជកព្រាហ្មណ៍ កាលនោះ ប្រថពី ដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ ព្រះឥន្ទ្របានក្លែងភេទជាព្រាហ្មណ៍ម្ដងទៀត ចុះមកសូមនាងមទ្រីទេវី ដែលមានសីល មានវត្តចំពោះប្ដី នឹងតថាគត ។ តថាគត មានសេចក្ដីត្រិះរិះក្នុងចិត្តដោយជ្រះថ្លា ចាប់នាងមទ្រីទេវីត្រង់ដើមដៃ ហើយច្រួចទឹក ដាក់លើអញ្ជលីនៃព្រាហ្មណ៍ ឱ្យនាងមទ្រីដល់ព្រាហ្មណ៍ ។ កាលដែលតថាគតឱ្យនាងមទ្រី ទេវតាឮដ៏អាកាស ក៏ត្រេកអររីករាយ ប្រថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងកាលនោះ ។ កាលតថាគតបរិច្ចាគជាលីកុមារ កណ្ហាជិនាធីតានិងនាង មទ្រីទេវី ដែលមានវត្តចំពោះប្ដី ឥតគិតក្ដៅក្រហាយសោះឡើយ ក៏ព្រោះហេតុនៃ

ពោធិញ្ញាណតែម្យ៉ាង ។ បុត្រទាំងពីរមិនមែនជាទីស្អប់របស់តថាគតទេ ទាំងនាងមទ្រី ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត បានជាតថាគតឱ្យបុត្រនិងភរិយាជាទីស្រឡាញ់ ។ កាលពួកជនមកជួបជុំគ្នា ក្នុងសំណាក់នៃមាតានិងបិតា ក្នុងព្រៃធំ ក៏ខ្សឹកខ្សួលដោយសេចក្ដីករុណា ចរចាសួរសុខនិងទុក្ខគ្នា ។ កាលមហាជនចូលទៅរកជនទាំងពីរ ជាអ្នកធ្ងន់ដោយហិរិនិងឱត្តប្បៈ កាលនោះ ប្រថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ក៏កំរើកញាប់ញ័រ ។ ម្យ៉ាងទៀត តថាគតចេញអំពីព្រៃធំ ជាមួយនិងពួកញាតិ ចូលទៅកាន់បុរី គួរជាទីសប្បាយឈ្មោះជេតុត្តរ ដែលជានគរដ៏ឧត្ដម ក្នុងកាលនោះ មហាមេឃក៏បង្អុរចុះនូវភ្លៀងជាវិការនៃកែវ ៧ ប្រការ ប្រថពីដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ក៏កម្រើក ។ ប្រថពីមិនមានចេតនាទេ មិនដឹងនូវសុខនឹងទុក្ខទេ តែមហាប្រថពីនោះ បានកំរើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត ។

ចប់ វេស្សន្តរចរិយា ទី ៩ ។

# សសបណ្ឌិតចរិយា ទី ១០

(១០) ចរិយាដទៃទៀត កាលតថាគតកើតជាទន្សាយ ត្រាច់ទៅក្នុងព្រៃ មានស្មៅ ស្លឹកឈើ បន្លែនិងផ្លែឈើជាអាហារ វៀរចាកការបៀតបៀនសត្វដទៃ ។ កាលនោះ ស្វា ចចក ភេនិង តថាគត ព្រមព្រៀងនៅជាមួយគ្នា ទាំងព្រឹកទាំងល្ងាច ។ តថាគត ប្រៀនប្រដៅសំឡាញ់ទាំង៣នោះ ដែលមានកិរិយាល្អនិងកិរិយា អាក្រក់ថា អ្នកទាំងឡាយ ចូរវៀរនូវអំពើអាក្រក់ ហើយចូរតម្កល់ ខ្ជាប់ក្នុងអំពើល្អ ។ តថាគតឃើញព្រះចន្ទ្រពេញវង់ ក្នុងថ្ងៃឧបោសថ ក៏ប្រាប់ដល់សំឡាញ់ទុំះ ក្នុងទីនោះថា ថ្ងៃនេះជាថ្ងៃឧបោសថ ។ អ្នកទាំងឡាយ ចូរចាត់ចែងទាន ដើម្បីឱ្យដល់ទក្ខិណេយ្យបុគ្គល លុះបានឱ្យទានដល់ទក្ខិណេយ្យបុគ្គលរួចហើយ ចូររក្សាឧបោសថ ។ សត្វជាសំឡាញ់នោះ បានទទួលពាក្យតថាគតថា សាធុ ហើយចាត់ ចែងទានតាមសេចក្តីអង់អាច តាមកម្លាំង ហើយស្វែងរកទក្ខិណេយ្យ បុគ្គល ។ ឯតថាគតដេកគិតនូវទានដែលសមគួរ ដល់ទក្ខិណេយ្យបុគ្គល ថា បើអញបានទក្ខិណេយ្យបុគ្គល តើអញនឹងឱ្យទានដូចម្តេច ។

ល្ងនិងសណ្តែកបាយនៃអញ គ្មានទេ សណ្តែករាជមាស អង្ករនិងខ្លាញ់នៃអញ ក៏គ្មានដែរ អញញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយស្មៅ អញមិនអាចនឹងឱ្យស្មៅបានទេ ដូច្នេះ បើមានទក្ខិណេយ្យបុគ្គលណាមួយដើរមកក្នុងសំណាក់អញដើម្បីភិក្ខា អញនឹងឱ្យខ្លួនជារបស់ខ្លួន និងមិនឱ្យទក្ខិណេយ្យបុគ្គលនោះ មានដៃទទេទៅវិញឡើយ ព្រះឥន្ទ្រដឹងនូវសេចក្តីត្រិះរិះរបស់តថាគត ហើយក្លែងភេទជាព្រាហ្មណ៍ ចូលមកកាន់លំនៅតថាគត ដើម្បីល្បងទានរបស់តថាគត ។ តថាគតឃើញឥន្ទព្រាហ្មណ៍នោះ ហើយក៏ត្រេកអរ បានពោលពាក្យនេះថា ពេញជាល្អមែនអ្នកមកក្នុងសំណាក់ខ្ញុំ ព្រោះហេតុតែអាហារ ។ ក្នុងថ្ងៃនេះ ខ្ញុំនឹងឱ្យនូវទានដ៏ ប្រសើរដល់អ្នក ជាទានដែលខ្ញុំមិនធ្លាប់ឱ្យឡើយ អ្នកប្រកបដោយគុណគឺសីល ការបៀតបៀនសត្វដទៃ មិនគួរដល់អ្នកឡើយ អ្នកចូរមក ចូរទៅនាំយកឧសផ្សេងៗមក បង្កាត់ភ្លើងឱ្យឆេះឡើង ខ្ញុំនឹងដុតខ្លួន អ្នកនឹងបានបរិភោគសាច់ឆ្អិន ។ ឥន្ទព្រាហ្មណ៍នោះ មានចិត្តត្រេកអរទទួលថា សាធុ ហើយទៅនាំឧសផ្សេង ៧ យកមកធ្វើជើងថ្ករយ៉ាងធំ ហើយធ្វើឱ្យមានផ្ទៃពេញដោយរងើកភ្លើង ។ គំនរភ្លើងធំនោះឆេះឆាប យ៉ាងណា ឥន្ទព្រាហ្មណ៍នោះ

ក៏ដុតភ្លើងឆេះសន្ធោក្នុងទីនោះ យ៉ាងនោះ តថាគតរលាស់ខ្លួនដែលប្រឡាក់ដោយធូលី ហើយអង្គុយក្នុងទីដ៏សមគួរនោះ ។ កាលណាគំនរឧសធំត្រូវភ្លើងឆេះ ឮសូរសម្លេងធុំធុំ កាលនោះ តថាគតលោតទំលាក់ខ្លួន ទៅក្នុងកណ្ដាលចន្លោះអណ្ដាតភ្លើង ធម្មតាទឹកត្រជាក់ដែលបុគ្គលណាមួយចុះទៅហើយ រមែងញ៉ាំងសេចក្ដីក្រវល់ក្រវាយក្ដៅក្រហាយឱ្យស្ងប់រម្ងាប់ បានញ៉ាំងសេចក្ដីត្រេកអរនិងបីតិឱ្យកើតឡើងយ៉ាងណា ។ កាលតថាគត ចូលទៅក្នុងភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ ក៏ញ៉ាំងសេចក្ដីក្រវល់ក្រវាយទាំងអស់ ឱ្យស្ងប់រម្ងាប់ដូចជាទឹកត្រជាក់ដូច្នោះឯង តថាគតបានឱ្យសម្បុរផ្ទៃ ស្បែក សាច់សរសៃ ឆ្អឹង បេះដូង និងកាយទាំងមូល មិនឱ្យសេសសល់ដល់ព្រាហ្មណ៍ ។

ចប់ សសបណ្ឌិតចរិយា ទី ១០ ។

## ឧទ្ទាននៃចរិយានោះ

អកិត្តិចរិយា ១ សង្ខព្រាហ្មណចរិយា ១ ស្តេចក្នុងដែនកុរុ ព្រះនាមធនញ្ជ័យ (កុរុធម្មចរិយា) ១ មហាសុទស្សនរាជ (សុទស្សនចរិយា) ១ មហាគោវិន្ទចរិយា ១ នេមិរាជចរិយា ១ ចន្ទកុមារចរិយា ១ សិវិរាជចរិយា ១ វេស្សន្តរចរិយា ១ សសបណ្ឌិតចរិយា ១ បុគ្គលណា បានឱ្យទានដ៏ប្រសើរទាំងឡាយនោះ ក្នុងកាលនោះ បុគ្គលនោះគឺតថាគតហ្នឹងឯង ។ ការបរិច្ចាគនូវទេយ្យធម៌ទាំងឡាយនុ៎ះ ជាបរិក្ខារនៃទាន ការបរិច្ចាគនូវទានដ៏ប្រសើរទាំងឡាយនុ៎ះ ជាបារមីនៃទាន (ហេតុនោះ) បានជាតថាគតឱ្យនូវជីវិតដល់យាចក ហើយបំពេញនូវបារមីនេះ ។ តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួនជារបស់ខ្លួន បុគ្គលអ្នកឱ្យទាន ស្មើដោយទានរបស់តថាគតមិនមានឡើយ នេះជាទានបារមីរបស់តថាគត ។

ចប់ ទានបារមី ។

# សីលបារមិតា

## សីលវនាគចរិយា ទី ១

(១១) កាលដែលតថាគតកើតជាដំរី ជាសត្វចិញ្ចឹមមាតា នៅក្នុងព្រៃធំ កាលនោះ នឹងរកអ្នកណាលើផែនដីនេះ ឱ្យស្មើនឹងតថាគត ដោយសីលគុណមិនមានឡើយ ។ មានថ្មើរព្រៃម្នាក់ឃើញតថាគតក្នុងព្រៃ ក៏ក្រាបទូលដល់ស្ដេចពារាណសីថា បពិត្រមហារាជ គជសារមួយ នៅក្នុងព្រៃធំ ជាសត្វមានសភាពសមគួរដល់ព្រះអង្គ ដំរីនោះមិនមានសេចក្ដីត្រូវការដោយស្នាមភ្លោះទេ មិនមានសេចក្ដីត្រូវការដោយខ្សែប្រកាំនិងរណ្ដៅទេ ដំរីនោះ គ្រាន់តែបុគ្គលចាប់ទាញប្រមោយ នឹងមកក្នុងទីនេះដោយខ្លួនឯង ។ ចំណែកខាងព្រះរាជា ទ្រង់បានព្រះសណ្ដាប់នូវពាក្យ របស់ថ្មើរព្រៃនោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរ ទើបទ្រង់ប្រើហ្មដំរី ដែលជាហត្ថាចារ្យឈ្លាសវាងវៃ បានសិក្សាវិជ្ជាចាប់ដំរីចេះល្អិតល្អ ។ ហ្មដំរីនោះលុះទៅដល់ ក៏ឃើញតថាគត កំពុងដកមើមឈូកក្រអៅឈូក

ក្នុងបទុមស្រះ ដើម្បីចិញ្ចឹមមាតា ។ នាយហត្ថាចារ្យនោះ លុះដឹងច្បាស់សីលគុណនៃតថាគត ក៏ពិចារណាឃើញលក្ខណៈ (នៃតថាគត) ហើយពោលថា ម្នាលកូន អ្នកចូរមក ហើយចាប់ដឹកតថាគតត្រង់ប្រមោយ ។ កាលនោះ កម្លាំងណា ប្រព្រឹត្តទៅក្នុងសរីរៈនៃតថាគត ដែលតាំងនៅដោយប្រក្រតី កម្លាំងនោះ ប្រាកដស្មើដោយកម្លាំងនៃដំរីច្រើនពាន់ ក្នុងថ្ងៃនេះ ។ បើតថាគតខឹង ចំពោះជនទាំងឡាយនោះ ដែលចូលមកចាប់តថាគ តថាគតអាច (នឹងញាំញីនូវជីវិត) នៃមនុស្សនោះ រហូតដល់រាជ្យជារបស់មនុស្សក៏បាន ។ តែតថាគតរក្សាសីល (សូម្បីឃើញ) នូវជនកាល ដាក់តថាគតក្នុងរោង ក៏មិនធ្វើចិត្តឱ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។ ប្រសិនបើជនទាំងឡាយនោះ កាប់ចាក់តថាគតដោយប៉ូវថៅនិងលំពែងស្នែងក្របី ក្នុងទីនោះ ក៏តថាគតមិនក្រោធខឹងចំពោះជនទាំងនោះ ព្រោះតថាគតខ្លាចដាច់សីល ។

ចប់ សីលវនាគចរិយា ទី ១ ។

# ភូរិទត្តចរិយា ទី ២

(១២) មានចរិយាដទៃទៀត កាលដែលតថាគតកើតជានាគឈ្មោះភូរិទត្ត មានឫទ្ធិច្រើន កាលនោះ តថាគតបានទៅកាន់តាវត្តិង្សទេវលោក ជាមួយនឹងមហារាជ ព្រះនាមវិរូបក្ខៈ ។ តថាគតបានឃើញ ទេវតាទាំងឡាយ ដែលឆ្អែតស្កប់ស្កល់ ដោយសេចក្ដីសុខយ៉ាងក្រៃលែង ក្នុងតាវត្តិង្សទេវលោកនោះ បានជាតថាគតសមាទាននូវសីលនិងវត្តដើម្បីទៅកាន់ស្ថានសួគ៌នោះ ។ តថាគត ធ្វើនូវកិច្ចថែទាំសរីរៈ បរិភោគគ្រាន់តែញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ អធិដ្ឋាននូវអង្គ ៤ ហើយ ដេកលើក្បាលដំបូក ។ កិច្ចដែលបុគ្គលណា គួរធ្វើដោយសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកនូវសម្បុរថ្ងៃ ស្បែក ដែលតថាគតឱ្យហើយនោះចុះ ។ អាលម្ពានព្រាហ្មណ៍ លុះនេសាទព្រាហ្មណ៍ ជាអកតញ្ញូប្រាប់កន្លែង ហើយក៏ទៅចាប់យកតថាគត ដាក់ក្នុងកំប្រោង ហើយប្រើតថាគតឱ្យលេង

ក្នុងស្រុក និគម និងជនបទនោះៗ ។ កាលអាលម្ពាយព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោងក្តី ញាំញីតថាគត ដោយដៃក្តី តថាគតមិនខឹងនឹងអាលម្ពាយព្រាហ្មណ៍ ព្រោះតថាគតខ្លាចដាច់សីល ។ ការបរិច្ចាគ ជីវិតនៃខ្លួន របស់តថាគត ជាធម្មជាតិស្រាលជាងបាច់ស្មៅទៅទៀត ឯការប្រព្រឹត្តកន្លងសីលនៃតថាគត ធ្ងន់ដូចជាការប្រែត្រឡប់ផែនដី ។ តថាគតលះបង់ជីវិតនៃតថាគតអស់រយជាតិ មិនមានចន្លោះ តថាគតមិនដែលទំលាយសីលព្រោះហេតុតែបានជា ស្តេចចក្រពត្តិ ក្នុងទ្វីបទាំង ៤ ទេ ។ ចំណែកខាងតថាគតរក្សាសីល (សូម្បីឃើញ) នូវអាលម្ពានព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោង ក៏មិនធ្វើចិត្តឱ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។

ចប់ ភូរិទត្តចរិយា ទី ២ ។

# ចម្បេយ្យចរិយា ទី ៣

(១៣) ចរិយាដទៃទៀត កាលដែលតថាគត កើតជាស្តេចនាគឈ្មោះចម្បេយ្យ មានឫទ្ធិច្រើន កាលនោះ តថាគតជាអ្នកប្រកបដោយធម៌ ជាអ្នកឆ្អែតស្កប់ស្កល់ដោយសីលនិងវត្ត ។ កាលនោះ ហ្មពស់ចាប់ តថាគត ដែលជាអ្នកប្រព្រឹត្តធម៌ រក្សាឧបោសថ យកទៅឱ្យលេងល្បែង ទៀបទ្វារក្រុងនៃស្តេច ។ ហ្មពស់នោះ គិតឱ្យមានពណ៌ខៀវ លឿង ក្រហម តថាគតធ្វើតាមចិត្តហ្មពស់ ឱ្យសម្រេចដូចគំនិតដែលគិត ។ តថាគតអាចនឹងធ្វើទីទួលឱ្យជាទីទឹក ធ្វើទីទឹកឱ្យជាទីទួល បើតថាគត ខឹងចំពោះហ្មពស់នោះ តថាគតអាចធ្វើឱ្យខ្ទេចជាផេះមួយរំពេច ។ បើតថាគតបណ្តោយតាមអំណាចចិត្ត តថាគតនឹងសាបសូន្យចាកសីល ប្រយោជន៍ដ៏ឧត្តម គឺភាពជាព្រះពុទ្ធ នឹងមិនសម្រេចដល់តថាគត ដែលសាបសូន្យចាកសីលឡើយ ។ កាយនេះ ទោះបែកធ្លាយរោយរាយ លើផែនដីនេះ ឱ្យដូចជាបុគ្គលរោយនូវសំដីស្រូវ ក៏តថាគតមិនទម្លាយ សីលឡើយ ។

ចប់ ចម្បេយ្យចរិយា ទី ៣ ។

# ចូឡពោធិចរិយា ទី ៤

(១៤) ចរិយាដទៃទៀត កាលដែលតថាគត ជាបរិញ្វាជក ឈ្មោះចូឡពោធិ ជាអ្នកមានសីលល្អឃើញនូវភពថា ជារបស់គួរខ្លាច ហើយ ក៏ចេញទៅសាងអភិនេស្រ្កម ។ នាងព្រាហ្មណីមានសម្បុរដូចមាស នាងជាភរិយារបស់តថាគត នាងមិនមានអាល័យក្នុងវដ្តៈ ក៏បាន ចេញទៅសាងអភិនេស្រ្កមដែរ នាងមិនមានអាល័យលះបង់នូវផៅពង្ស មិនជាប់នឹងពួកត្រកូល តថាគតនឹងព្រាហ្មណីនោះ ដើរទៅកាន់ស្រុកនិងនិគម ក៏បានចូលទៅកាន់ក្រុងពារាណសី ។ យើងទាំងពីរនាក់ជាអ្នកមានបញ្ញា នៅជិតក្រុងពារាណសីនោះ មិននៅច្រឡូកច្រឡំនឹងពួកត្រកូលទេ នៅក្នុងឱទ្យានស្ងេច ជាទីមិនមានសម្លេង មិនមានវិករវ ។ ព្រះរាជាទ្រង់ស្ដេចទៅទតឱទ្យាន បានឃើញព្រាហ្មណី ទ្រង់ចូលទៅសួរតថាគតថា ស្រីនេះជាភរិយារបស់លោក ឬជាភរិយារបស់អ្នកណា ។ កាលព្រះរាជា ទ្រង់ត្រាស់សួរយ៉ាងនេះហើយ តថាគតបានទូលព្រះរាជាថា ស្រីនេះមិនមែន

ជាភរិយារបស់អាត្មាភាពទេ គ្រាន់តែជាស្រីមានធម៌ត្រូវគ្នា មានសាសនាត្រូវគ្នាតែប៉ុណ្ណោះ ។ ព្រះរាជាមានព្រះទ័យ ប្រតិព័ទ្ធចំពោះបរិព្វាជិកានោះ ក៏ប្រើព្រះរាជបុរសឱ្យចាប់ សង្កត់សង្កិន ដោយកម្លាំងយកចូលទៅក្នុងព្រះរាជវាំង ។ កាលភរិយា មានជាតិជាមួយគ្នា មានសាសនាត្រូវគ្នារបស់តថាគត ដែលរាជបុរសអូសនាំទៅនោះ សេចក្តីក្រោធក៏កើតឡើងដល់តថាគត ។ កាលសេចក្តីក្រោធកើតឡើង តថាគតពិចារណានូវសីលវត្ត ផ្ចាញ់ផ្ចាល់នូវសេចក្តីក្រោធក្នុងទីនោះ មិនឱ្យចំរើនឡើងបាន បើប្រសិនជាអ្នកណាមួយ ចាក់ព្រាហ្មណីនោះ ដោយលំពែងដ៏មុត តថាគតក៏មិនទំលាយសីល ព្រោះហេតុនៃពោធិញ្ញាណ ព្រាហ្មណីនោះ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងកម្លាំងតថាគត ក៏មិនមែនជាមិនមានឡើយ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតរក្សាសីលតែម្យ៉ាង ។

ចប់ ចូឡពោធិចរិយា ទី ៤ ។

# មហិសរាជចរិយា ទី ៥

(១៥) មានចរិយាដទៃទៀត កាលតថាគតកើតជាក្របីព្រៃត្រាច់ទៅក្នុងព្រៃធំ មានកាយចំរើន មានកម្លាំងច្រើន មានសរីរៈធំធាត់ បើគេឃើញហើយគួរតែខ្លាច ។ ទីនៅនៃក្របីទាំងឡាយ មានក្នុងទីនោះ គឺញកភ្នំ ផ្លូវជិតភ្នំដែលបុគ្គលទៅបានដោយកម្រ គល់ឈើនិងបឹង សត្វនីមួយៗ កាលត្រេចទៅក្នុងទីនោះៗ តែងបានឃើញទីដ៏ល្អក្នុងព្រៃធំ ឯតថាគតក៏ចូលទៅកាន់ទីនោះ ឈរផង ដេកផង ។ គ្រានោះ មានស្វាមួយក្នុងព្រៃធំនោះ ជាសត្វលាមកថោកទាបឡេះឡោះ មកកាន់ទីនោះ នោម ជុះដាក់តថាគត ត្រង់ក ថ្ងាសនិងចិញ្ចើម ។ ពានរនោះ ប្រទូស្តនឹងតថាគត អស់មួយថ្ងៃ ពីរថ្ងៃបីថ្ងៃ បួនថ្ងៃ តថាគតត្រូវពានរនោះ បៀតបៀនសព្វៗកាល ។ ទេវតាឃើញតថាគត ដែលត្រូវស្វានោះបៀតបៀនហើយ ក៏ពោលពាក្យនេះនឹងតថាគតថា (ម្នាលក្របី) អ្នកចូរញ៉ាំងស្វាលាមក

អាក្រក់នេះ ឱ្យវិនាសដោយស្នែង និងក្រចកទៅ ។ កាលទេវតាពោលយ៉ាងនេះហើយ តថាគតបាន និយាយតបទៅនឹងទេវតានោះវិញថា (ម្នាលទេវតា) បើទុកជាអ្នកប្រឡាក់ខ្ញុំដោយសាកសពលាមក ថោកទាប ដូចម្ដេចក៏ដោយ ក៏ខ្ញុំមិនធ្វើតាមពាក្យអ្នកឡើយ ។ ព្រោះថាបើខ្ញុំខឹងនឹងស្វានេះ ខ្ញុំជាបុគ្គល ថោកទាប ជាងស្វានោះទៅទៀត សីលរបស់ខ្ញុំ នឹងបែកធ្លាយផង វិញ្ញូជនទាំងឡាយ នឹងតិះដៀលដល់ខ្ញុំផង ។ ការស្លាប់ព្រោះសេចក្ដីបរិសុទ្ធិ ប្រសើរជាងការរស់នៅ ដែលពួកអ្នកប្រាជ្ញតិះដៀល បើយ៉ាងនេះ ឱ្យខ្ញុំធ្វើនូវការបៀតបៀនអ្នកដទៃ ព្រោះហេតុនៃជីវិត (របស់ខ្លួន) ដូចម្ដេចកើត ។ បុគ្គលប្រកបដោយប្រាជ្ញា កាលអត់ទ្រាំ ចំពោះសេចក្ដី មើលងាយ (របស់ពួកជនដទៃ) ក្នុងហេតុយ៉ាងមុទុ មជ្ឈិម និងឧក្រិដ្ឋ រមែងបានសម្រេច ដូចសេចក្ដីប្រាថ្នាក្នុងចិត្ត យ៉ាងនេះឯង ។

ចប់ មហិសរាជចរិយា ទី ៥ ។

# រុរុមិគចរិយា ទី ៦

(១៦) មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចម្រឹគឈ្មោះរុរុ សម្បុរស្បែកដូចមាសដែលជាងដុតល្អ ប្រកបដោយសីលដ៏ឧត្តម ។ កាលនោះប្រទេសដែលគួរឱ្យត្រេកអរ គួរឱ្យរីករាយ ជាប្រទេសស្ងាត់ស្ងួន្យ មិនមានមនុស្ស នៅជិតច្រាំងទន្លេគង្គា គួរជាទីរីករាយនៃចិត្ត តថាគតបានចូលទៅនៅក្នុងទីនោះ ។ កាលនោះមានបុរសម្នាក់ (ចំពាក់បំណុលគេ) ត្រូវពួកម្ចាស់ទ្រព្យតឹងទារខ្លាំងក៏លោតទំលាក់ខ្លួនចុះ ក្នុងទីខាងលើខ្សែទឹកទន្លេគង្គា ដោយគិតថាអញរស់ក៏ដោយស្លាប់ក៏ដោយ ។ បុរសនោះ ត្រូវខ្សែទឹកទន្លេគង្គាកួចទៅក្នុងទឹកធំ អស់មួយយប់មួយថ្ងៃ ស្រែកនូវសំរែកគួរឱ្យអាណិត អណ្តែតទៅ ក្នុងកណ្តាលទន្លេ ។ តថាគតឮសម្លេងនៃបុរសនោះ កំពុងខ្សឹកខ្សួល គួរអាណិត ឋិតនៅទៀបឆ្នេរនៃស្ទឹង ក៏ស្រែកសួរថា អ្នកជាមនុស្សឬ ។ បុរសនោះ ដែលតថាគតសួរហើយ ក៏ប្រាប់ហេតុរបស់ខ្លួន ក្នុងកាលនោះថា ខ្ញុំភ័យតក់ស្លុតខ្លាំងនឹងពួកម្ចាស់បំណុល ហើយស្ទុះមកក្នុងស្ទឹងធំនេះ ។ តថាគតមានសេចក្តីអាណិត

ចំពោះបុរសនោះ ក៏ប្រថុយលះបង់ជីវិតរបស់ខ្លួន ចូលទៅនាំយកបុរសនោះមក ក្នុងរាត្រីដ៏ងងឹត ។ តថាគត ដឹងនូវកាលនៃបុរសនោះបានសេចក្តីលំបាកហើយ ក៏ពោលពាក្យនេះនឹងបុរសនោះថា ខ្ញុំសូមពរមួយនឹងអ្នកថា ចូរអ្នកកុំប្រាប់រូបខ្ញុំដល់អ្នកណាមួយឡើយ ។ បុរសនោះ ទៅកាន់នគរវិញ ស្តេចសួរហេតុតែចង់បានទ្រព្យ ក៏ក្រាបទូល(ដល់ស្តេច) ហើយនាំស្តេចចូលទៅកាន់សំណាក់តថាគត ។ តថាគត ប្រាប់ហេតុសព្វគ្រប់ដល់ស្តេច ស្តេចលុះបានស្តាប់ ពាក្យនោះហើយ ក៏បានសម្រេចព្រះទ័យថា ត្រូវសម្លាប់បុរសនេះ ដោយកូនសរ (ទ្រង់ត្រាស់ថា) អញនឹងសម្លាប់បុរសទ្រុស្តមិត្រដ៏អាក្រក់ ក្នុងទីនេះ ។ តថាគតកាលរក្សានូវបុរសនោះ ក៏ស៊ូប្តូរខ្លួនបុរសនោះ ដោយខ្លួនរបស់តថាគត (ក្រាបទូលថា) បពិត្រមហារាជ បុរសនុ៎ះ ចូររស់នៅចុះ សូមព្រះអង្គធ្វើខ្ញុំព្រះអង្គតាមប្រាថ្នាវិញ ។ តថាគតរក្សាសីលរបស់តថាគត មិនរក្សាជីវិតរបស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលម៉ត់ចត់ ព្រោះហេតុតែពោធិញ្ញាណ ។

ចប់ រុរុមិគចរិយា ទី ៦ ។

# មាតង្គចរិយា ទី ៧

(១៧) មានចរិយាដទៃទៀត កាលតថាគត កើតជាជដិលតាបសឈ្មោះ មាតង្គៈ មានតបៈខ្ពង់ខ្ពស់ មានសីលបរិសុទ្ធ មានចិត្តតំកល់មាំល្អ ។ ជនពីរនាក់ គឺតថាគតនិងព្រាហ្មណ៍ នៅជិតឆ្នេរទន្លេគង្គា តថាគតនៅខាងលើខ្សែទឹក ឯព្រាហ្មណ៍នៅខាងក្រោមខ្សែទឹក ។ ព្រាហ្មណ៍ កាលដើរទៅតាមឆ្នេរទន្លេ បានឃើញអាស្រមតថាគត នៅខាងលើខ្សែទឹក ក៏ប្រទេចផ្តាសាតថាគតក្នុងទីនោះ ហើយដាក់សម្បថថា (ចូរឱ្យក្បាលអ្នកបែកជា ៧ ភាគ ក្នុងថ្ងៃទី ៧) ។ បើតថាគតខឹងនឹងព្រាហ្មណ៍ មានតែតថាគតមិនរក្សាសីល តថាគតនឹងក្រឡេកមើលព្រាហ្មណ៍នោះ ហើយធ្វើឱ្យឆេះទៅជាផេះក៏បាន ។ កាលណោះ ព្រាហ្មណ៍នោះ មានចិត្តប្រទូស្តខឹង ដាក់សម្បថដល់តថាគត ដោយឧបាយណាសម្បថនោះ បែរជាធ្លាក់លើក្បាលព្រាហ្មណ៍នោះវិញ តថាគតដោះព្រាហ្មណ៍នោះ ឱ្យរួចចាកសម្បថ ដោយឧបាយនោះ ។ តថាគតរក្សាសីលរបស់តថាគត មិនរក្សាជីវិតរបស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលម៉ត់ចត់ ព្រោះហេតុនៃពោធិញ្ញាណ ។

ចប់ មាតង្គចរិយា ទី ៧ ។

# ធម្មទេវបុត្តចរិយា ទី ៨

(១៨) មានចរិយាដទៃទៀត កាលតថាគតកើតជាទេវបុត្រ មានអានុភាពច្រើន ឈ្មោះធម្មៈ មានសក្តិធំ មានឫទ្ធិច្រើន ជាអ្នកអនុគ្រោះដល់សត្វលោកទាំងពួង ។ កាលនោះ តថាគតញ៉ាំងមហាជនឱ្យតម្កល់នៅក្នុងកុសលកម្មបថ១០ត្រាច់ទៅក្នុង ស្រុកនិង និគម ជាមួយនឹងមិត្រ ជាមួយនឹងជនជាបរិវារ ។ មានទេវបុត្រមួយ អង្គមានធម៌លាមក កំណាញ់ស្វិតស្វាញ សម្តែងនូវធម៌លាមក ១០ ប្រការ ទេវបុត្តនោះត្រេចទៅលើផែនដីដ៏ធំ ក្នុងជម្ពូទ្វីបនេះ ជាមួយនឹងមិត្តជាមួយនឹងជនជាបរិវារ ។ យើងជាទេវបុត្តទាំងពីរនាក់ គឺ ទេវបុត្តអ្នកពោលនូវធម៌ និងទេវបុត្តអ្នកពោលនូវអធម៌ ទៅជាសត្រូវនឹងគ្នា យើងទាំងពីរនាក់ ត្រូវបររថប៉ះទឹមដោយនឹម ក្នុងផ្លូវជួបគ្នា ។ ជម្លោះជាហេតុញ៉ាំងភ័យឱ្យកើត ប្រព្រឹតទៅដល់ កល្យាណទេវបុត្រនិងបាបទេវបុត្តមហាសង្គ្រាម ក៏តាំងឡើង ដើម្បីប្រជែងផ្លូវគ្នា ។ បើតថាគតខឹងនឹងអធម្មទេវបុត្ត មានតែតថាគតទំលាយនូវតបោគុណ គឺសីលដ៏ប្រសើរ តថាគតគប្បីធ្វើនូវអធម្មទេវបុត្តនោះ ព្រមទាំងជន

ជាបរិស័ទឱ្យទៅជាធូលីក៏បាន ។ ប៉ុន្តែតថាគតរំលត់ចិត្ត ដើម្បីរក្សាសីល តថាគតព្រមទាំងជនជាបរិស័ទក៏បរចៀស បើកផ្លូវឱ្យបាបទេវបុត្ត ។ កាលតថាគតព្រមទាំងជនជា បរិស័ទ រំលត់ចិត្តបររថចៀសអំពីផ្លូវហើយ មហាប្រថពី ក៏ស្រូបបាបទេវបុត្ត ក្នុងខណៈនោះ ។

ចប់ ធម្មទេវបុត្តចរិយា ទី ៨ ។

# ជយទិសចរិយា ទី ៩

(១៩) មានស្តេចមួយអង្គព្រះនាមថា ជយទិស ប្រកបដោយសីលគុណ ក្នុងក្រុងដ៏ឧត្តម ឈ្មោះកប្បិលា ជាក្រុងដ៏ប្រសើរ ក្នុងដែនបញ្ចាល ។ តថាគតកើតជាព្រះរាជបុត្ត របស់ស្តេចនោះឈ្មោះអលីនសត្តកុមារ ជាអ្នកល្បីល្បាញក្នុងធម៌ មានសីលដ៏ល្អ ប្រកបដោយមហាបុរិសគុណ ជាអ្នករក្សានូវជនជាបរិវារសព្វកាល ។ បិតារបស់តថាគត បានទៅប្រពាតម្រឹគ(ក្នុងព្រៃ) ជ្រុលចូលទៅកាន់សំណាក់យក្ស ឈ្មោះបោរិសាទ យក្សនោះចាប់ស្តេចជយទិស ជាបិតា

នៃតថាគត ( ហើយនិយាយថា) អ្នកត្រូវជាអាហាររបស់យើងហើយ អ្នកកុំកំរើកឡើយ ។ បិតារបស់តថាគតនោះ លុះឮពាក្យរបស់យក្ខិនីបុត្តនោះហើយ ក៏ភ័យតក់ស្លុត ញ័ររន្ធត់ រឹងភ្លៅទាំងពីរ បិតានៃតថាគតនោះ ឈរនៅស្ងៀម មិនអាចនឹងរត់ចេញទៅបាន ព្រោះឃើញស្តេចបោរិសាទ ។ ព្រះរាជាទ្រង់អង្វរថា សូមអ្នកយកសាច់ម្រឹគនេះចុះ សូមលែងខ្ញុំ ខ្ញុំនឹងឱ្យទ្រព្យដល់ព្រាហ្មណ៍ រួចហើយនឹងត្រឡប់មកវិញ ។ បិតាហៅតថាគត មកប្រាប់ថា ម្នាលកូនអ្នកចូរគ្រប់គ្រងរាជ្យ ចូរកុំប្រមាទបុរីនេះឡើយ ដែលអញបានត្រឡប់មកវិញនេះ ព្រោះតែអញបានប្តេជ្ញាជាមួយនឹងយក្សបោរិសាទ ។ តថាគតថ្វាយបង្គំព្រះមាតានិងព្រះបិតា ហើយនិម្មិតខ្លួនកាន់ធ្នូនិងព្រះខាន់ ចេញអំពីនគរ ដើរចូលទៅរកបោរិសាទយក្ស ។ ( តថាគតគិតថា យក្សនេះបើឃើញតថាគត) មានគ្រឿងសាស្ត្រាវុធ នៅក្នុងដៃ ក៏នឹងតក់ស្លុត កាលបើតថាគតធ្វើយក្សនោះឱ្យតក់ស្លុត សីលរបស់តថាគត នឹងបែកធ្លាយដោយការញ៉ាំងសេចក្តីតក់ស្លុត ឱ្យកើតដល់យក្សនោះ ។ ( លុះគិតឃើញយ៉ាងនេះ) តថាគតមិនពោលពាក្យជាទីស្អប់ ទៅរកយក្សនោះទេ ព្រោះការខ្លាចដាច់សីលនៃតថាគត

តថាគតមានមេត្តាចិត្ត ពោលតែពាក្យមានប្រយោជន៍ ហើយបាន ពោលនូវពាក្យនេះថា ចូរលោកតាដុតភ្លើងឱ្យឆេះខ្លាំងឡើង ខ្ញុំនឹង លោតពីដើមឈើនេះទម្លាក់ទៅ(ក្នុងភ្លើងនោះ) បពិត្រជីតា បើ លោកតាដឹងនូវកាលនៃសាច់នោះឆ្អិនល្អហើយ ចូរបរិភោគសាច់នោះ ចុះ ។ ព្រោះហេតុ បិតាមានសីល ដូចរៀបរាប់មកនេះ តថាគតមិន រក្សាជីវិតរបស់តថាគតទេ តថាគតញុំាងបោរិសាទ ជាអ្នកធ្វើអំពើ បាណាតិបាត ឱ្យវៀរបង់អំពើអាក្រក់សព្វកាល ។

ចប់ ជយទិសចរិយា ទី ៩ ។

# សង្ខបាលចរិយា ទី ១០

(២០) មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចនាគ ឈ្មោះសង្ខបាល មានឫទ្ធច្រើន មានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក មានអណ្តាតពីរ ជាសត្វគ្របសង្កត់ឱរគជាតិ ។ តថាគតអធិដ្ឋានអង្គ ទាំង ៤ ជិតផ្លូវធំ ៤ ជាកន្លែងទៅមកនៃជនផ្សេងៗ ហើយសម្រេចនូវ

ការនៅក្នុងទីនោះ ។ បុគ្គលណាមានកិច្ចគួរធ្វើដោយអវយវៈនេះគឺ សម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយក អវយវៈដែលអញឱ្យហើយចុះ ។ កូនព្រានព្រៃទាំងឡាយ ជាមនុស្ស រឹងត្អឹងអាក្រក់ឥតមានអាណិតអាសូរ មានដំបង ៤ ជ្រុងក្នុងដៃ បាន ឃើញតថាគត ហើយដើរចូលមកក្នុងទីនោះ ។ កូនព្រានព្រៃ ទាំងឡាយ បានចោះតថាគតត្រង់ ច្រមុះ កន្ទុយ ខ្នង និងកហើយ លើកតថាគតដាក់ក្នុងសម្រែក រែកយកទៅ ។ តថាគត បើប្រាថ្នានឹង ធ្វើមហាប្រថពីដែលមានសមុទ្រជាទីបំផុត ព្រមទាំងឈើព្រៃ ព្រម ទាំងភ្នំឱ្យឆេះខ្ទេចទៅជាផេះ ដោយខ្យល់តាមច្រមុះ ក្នុងទីនោះក៏បាន ។ (ប៉ុន្តែ) តថាគត មិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយ ដែកស្រួច និងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមី របស់តថាគត ។

ចប់ សង្ខបាលចរិយា ទី ១០ ។

## ឧទានដៃនចរិយានោះ

សីលវនាគចរិយា ១ ភូរិទត្តចរិយា ១ ចម្បេយ្យចរិយា ១ ចូឡពោធិចរិយា ១ មហិសរាជចរិយា ១ រុរុមិគចរិយា ១ មាតង្គចរិយា ១ ទេវធម្មបុត្តចរិយា ១ ជយទិសចរិយា ១ សង្ខបាលចរិយា ១ ។ ចរិយា ទាំងអស់នោះ តថាគតសំដែងហើយថា មានសីលជាកម្លាំង ជាបរិក្ខារ តថាគតបានគ្រប់គ្រងជីវិត រក្សាសីល ។ កាលតថាគត ជាសង្ខបាលនាគរាជបានប្រគល់ជីវិតឱ្យដល់បុគ្គលណាមួយ សព្វៗកាល ហេតុនោះ បារមីនោះ ជាសីលបរមត្ថបារមី (នៃតថាគត) ។

ចប់ សីលបារមីនិទ្ទេស ។

# នេក្ខម្មបារមី
# យុធញ្ជយចរិយា ទី ១

(២១) កាលដែលតថាគត កើតជារាជបុត្ត (នៃស្តេចសព្វទត្ត) ឈ្មោះយុធញ្ជ័យ ជារាជកុមារមានបរិវារនិងយសរាប់មិនបាន ក្នុងកាលនោះ តថាគតកើតសេចក្តីសង្វេគ ព្រោះឃើញដំណក់ទឹកសន្សើមដែលរីងហួតដោយកំដៅព្រះអាទិត្យ ។ តថាគតយកដំណក់ទឹកសន្សើមនោះជាអធិបតី ចម្រើននូវសេចក្តីសង្វេគ ថ្វាយបង្គំព្រះមាតា និងព្រះបិតា ហើយសូមបព្វជ្ជា ។ ពួករាជបុរសព្រមទាំងអ្នកនិគម អ្នកនៅក្នុងដែន ផ្គងអញ្ជលីអង្វរតថាគតថា បពិត្រព្រះរាជបុត្ត សូមព្រះអង្គ ម្ចាស់គ្រប់គ្រងមហាប្រថពី ដែលសម្រេចដោយសម្បត្តិដ៏ស្តុកស្តម្ភក្នុងថ្ងៃនេះចុះ ។ តថាគតមិនមានអាល័យ លះបង់រាជបុរស ព្រមទាំងស្តេច ស្រីស្នំ អ្នកនិគម និងអ្នកនៅក្នុងដែន ដែលកំពុងខ្សឹកខ្សួលគួរឱ្យអាណិត ។ តថាគតលះបង់រាជ្យលើផែនដី ញាតិជនជាបរិស័ទ និងយសទាំងអស់ ឥតមានគិតដល់ ព្រោះហេតុ ពោធិញ្ញាណតែម្យ៉ាង ។ មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជា តថាគតលះបង់រាជ្យ ។

ចប់ យុធញ្ជយចរិយា ទី ១ ។

# សោមនស្សចរិយា ទី ២

(២២) មានចរិយាដទៃទៀត កាលដែលតថាគត កើតជារាជបុត្ត (នៃស្តេចកុរុរាជ) ក្នុងឥន្ទបត្តបុរីដ៏ឧត្តម មានឈ្មោះប្រាកដថា សោមនស្សកុមារ ជារាជបុត្តដែលជនទាំងឡាយ មានមាតាបិតាជាដើម ស្រឡាញ់ពេញចិត្តក្រៃលែង ជាអ្នកមានសីល ប្រកបដោយគុណ មានសំដីពីរោះ គោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ មានហិរិទាំងមានសេចក្តីឈ្លាសវៃក្នុងសង្គហធម៌ (៤ យ៉ាង) ។ មានតាបសកុហកម្នាក់ ជាអ្នកស្និទ្ធស្នាលនៃស្តេចកុរុនោះ ដាំសួនច្បារ និងគុម្ពផ្កាចិញ្ចឹមជីវិត ។ តថាគតឃើញកុហកតាបសនោះ ដូចគំនរអង្កាមមិនមានគ្រាប់អង្ករ ដូចឈើមានប្រហោងក្នុង ឬដូចដើមចេកមិនមានខ្លឹម ក៏ត្រិះរិះថា សប្បុរសធម៌ មានឈានជាដើម នៃតាបសនេះមិនមានទេ តាបសនេះ ជាបុគ្គលប្រាសចាកភាពជាសមណៈ លះបង់សុក្កធម៌ គឺហិរិនិងឱត្តប្បៈ ព្រោះហេតុតែការចិញ្ចឹមជីវិត ។ ក្នុងបច្ចន្តប្រទេស មានពួកចោរនៅក្នុងព្រៃធំបះបោរ បិតារបស់តថាគត ទៅបង្ក្រាបបច្ចន្តប្រទេសនោះ បានផ្តាំ(តថាគតថា) ម្នាលកូន ចូរបាកុំធ្វេសប្រហែស ចំពោះជដិលដែលមាន តបៈដ៏ខ្ពង់ខ្ពស់ ចូរបាញុំាងជដិលនេះ

ឱ្យប្រព្រឹត្តទៅតាមសេចក្ដីប្រាថ្នាចុះ ព្រោះតាបសនោះ ជាអ្នកឱ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ តថាគតទៅកាន់ទី បំរើតាបសនោះបានពោលនូវពាក្យនេះថា ម្នាលគហបតីអ្នកសុខ សប្បាយទេឬពួកអ្នកជំនួញនាំ (មាសនិងប្រាក់) មកឱ្យអ្នកដែរឬ ។ ព្រោះពាក្យដែលតថាគត ពោលថាគហបតី កុហកតាបសនោះអាស្រ័យនូវមានះក៏ខឹង(និយាយថា) ក្នុងថ្ងៃនេះ អាត្មាភាពនឹងឱ្យស្ដេចសម្លាប់ទ្រង់ ឬឱ្យបំបរបង់ទ្រង់ចាកដែន ។ លុះព្រះរាជាបង្ក្រាបបច្ចន្តប្រទេសរួចហើយ (ត្រឡប់មកនគរវិញ ស្ដេចចូលទៅកាន់ឧទ្យាន) ទ្រង់ត្រាស់សួរកុហកតាបសថា (បពិត្រលោកម្ចាស់ដ៏ចំរើន) ចុះលោកល្មមអត់ទ្រាំបានទេឬ រាជកុមាររាប់អានលោកស្រួលបួលទេឬ ។ តាបសបាបនោះ បានទូលព្រះរាជានោះ តាមដែលខ្លួនអាចឱ្យព្រះរាជកុមារវិនាស ព្រះរាជាជាម្ចាស់ផែនដី ទ្រង់ព្រះសណ្ដាប់ពាក្យនេះ របស់តាបសនោះ ហើយត្រាស់បង្គាប់ពួកពេជ្ឈឃាតថា អ្នកទាំងឡាយ(បើឃើញកុមារក្នុងទីណា) ចូរកាត់ក្បាលចិញ្ច្រាំជាបួនកំណាត់ហើយកប់ក្នុងផ្លូវច្រក បង្ហាញជនដទៃឱ្យឃើញថា នេះជាគតិដែលបៀតបៀនជដិល ។ ពួកពេជ្ឈឃាតទាំងនេះ កាច អាក្រក់ មិនមាន

សេចក្ដីអាណិត ទៅក្នុងទីនោះ ហើយទាញតថាគត ដែលអង្គុយលើចង្កេះមាតានាំយកទៅ ។ តថាគតនិយាយនឹងជនទាំងនោះ ដែលកំពុងចងដោយចំណងដ៏មាំថា រាជកិច្ចមានដល់ខ្ញុំ សូមអ្នកទាំងឡាយនាំខ្ញុំទៅជួបនឹងស្ដេចមួយរំពេចសិន ។ ពួកពេជ្ឈឃាតទាំងនោះ នាំតថាគតទៅជួបនឹងស្ដេច ដែលសេពគប់នឹងតាបសលាមក លុះតថាគតបានជួប ក៏ញ៉ាំងស្ដេចឱ្យដឹងច្បាស់នូវ ការប្រព្រឹត្តនៃតាបសនោះ ព្រមទាំងញ៉ាំងស្ដេចឱ្យលុះក្នុងអំណាចតថាគត ។ ព្រះរាជាជាបិតារបស់តថាគតនោះ សូមទោសតថាគតក្នុងទីនោះ ហើយប្រទាននូវភាពជាស្ដេចធំដល់តថាគត តែតថាគតនោះឯង ទំលាយនូវងងឹតចូលទៅកាន់ផ្នួសវិញ ។ ភាពនៃខ្លួនជាស្ដេចធំ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងការបរិភោគកាម ក៏មិនមែនជាទីស្អប់នៃតថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត បានជាតថាគតលះបង់រាជ (ចូលទៅកាន់ផ្នួស) ។

ចប់ សោមនស្សចរិយា ទី ២ ។

# អយោឃរចរិយា ទី ៣

(២៣) មានចរិយាដទៃទៀត កាលដែលតថាគត កើតជារាជកុមារឈ្មោះ អយោឃរៈ ជាឱរសនៃព្រះបាទកាសិករាជ ចំរើនវ័យវឌ្ឍនាការ ក្នុងផ្ទះជាវិការនៃដែក ។ ព្រះរាជបិតារបស់តថាគតទ្រង់ត្រាស់នឹងតថាគតថា ម្នាលកូន ជីវិត(របស់កូន) រស់នៅបានដោយលំបាក បិតាចិញ្ចឹមថែរក្សាកូនក្នុងផ្ទះជាវិការនៃដែក ដ៏ចង្អៀតចូរកូន គ្រប់គ្រងមហាប្រថពី ទាំងមូលនេះព្រមទាំងដែន និគមនិងពួកជនក្នុងថ្ងៃនេះ ។ តថាគតថ្វាយបង្គំប្រណម្យអញ្ជលី នូវព្រះមហាក្សត្រហើយ ពោលនូវពាក្យនេះថា ពពួកសត្វណាមួយលើផែនដីជាសត្វថោកទាបឬខ្ពង់ខ្ពស់ និងកណ្តាល សត្វទាំងនោះ ពុំមានការរក្សាឡើយ តែងចំរើនឡើង ក្នុងផ្ទះរបស់ខ្លួន ជាមួយនឹងពួកញាតិរបស់ខ្លួន ចំឡែកតែខ្ញុំព្រះអង្គ មានការចិញ្ចឹមក្នុងផ្ទះជាវិការនៃដែកដ៏ចង្អៀតនេះ ចាត់ទុកជា ការខ្ពង់ខ្ពស់ក្នុងលោក ខ្ញុំចំរើនវ័យក្នុងផ្ទះជាវិការនៃដែក ដែលពុំមានពន្លឺ ព្រះចន្ទនិងព្រះអាទិត្យ។ ខ្ញុំប្រសូតចេញចាកផ្ទៃនៃមាតា ដែលពេញដោយសាកសព មានក្លិនស្អុយ

ហើយត្រូវគេដាក់ក្នុងផ្ទះជាវិការនៃដែកទៀត បានសេចក្តីទុក្ខយ៉ាងខ្លាំង ជាងកាលដែលនៅក្នុងផ្ទៃនៃមាតានោះទៅទៀត ។ ខ្ញុំបានសេចក្តីទុក្ខ អាក្រក់ក្រៃលែងប្រាកដដូច្នោះ បើខ្ញុំនៅត្រេកអរនឹងរាជ្យ ខ្ញុំជាបុគ្គលថោកទាបបំផុត ជាងបុរសលាមកទៅទៀត ។ ខ្ញុំជាបុគ្គលនឿយណាយ នឹងកាយស្អុយ ពុំត្រូវការដោយរាជ្យឡើយ ខ្ញុំស្វែងរកនូវទីដែលមច្ចុរាជ ញាំញីមិនបាននោះ ដែលជាទីរំលត់នូវទុក្ខ ។ តថាគតលុះគិតយ៉ាងនេះហើយ ពួកមហាជនក៏យំស្រែក តថាគតកាត់នូវចំណង(គឺតណ្ហា) ហើយចូលទៅកាន់ព្រៃធំ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់របស់តថាគតដែរតែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់នៃតថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ។

ចប់ អយោឃរចរិយា ទី ៣ ។

# តីសចរិយា ទី ៤

(២៤) មានចរិយាដទៃទៀត កាលដែលតថាគត កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងពារាណសី ដែនកាសី មានបងប្អូនស្រីនិងបងប្អូនប្រុស ៧ នាក់ ។ តថាគតជាចំបងនៃជនទាំង៧នាក់នុ៎ះ ប្រកបដោយសុក្កធម៌ហិរិ ឃើញនូវភព(មានកាមភពជាដើម) ថាគួរខ្លាចហើយត្រេកអរក្នុងនេក្ខម្មៈ ។ ពួកសម្លាញ់មានអធ្យាស្រ័យត្រូវគ្នាដែលមាតា បិតាប្រើទៅអញ្ជើញតថាគត ដោយកាមទាំងឡាយថា ចូរអ្នកទ្រទ្រង់ វង្សត្រកូលចុះ ។ ពាក្យណាដែលពួកសម្លាញ់ទាំងនុ៎ះបានពោលហើយ ជាពាក្យនាំមកនូវសេចក្តីសុខ ក្នុងគិហិភាពពាក្យនោះជាពាក្យអាក្រក់សំរាប់ខ្ញុំ ដូចជាភាជន៍ដ៏ក្តៅ ។ កាលនោះពួកសម្លាញ់ទាំងនោះ សួរសេចក្តីប្រាថ្នារបស់តថាគត នឹងតថាគតដែលជាអ្នកបោះបង់នូវកាមថា ម្នាលសម្លាញ់ បើអ្នកមិនបរិភោគកាមទេ អ្នកចង់បានអ្វីទៅវិញ ។ តថាគតជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន

បានពោលពាក្យនេះប្រាប់ពួក សម្លាញ់ទាំងនោះ ដែលស្វែងរកប្រយោជន៍(ដល់តថាគត)ថា ខ្ញុំត្រេកអរក្នុងនេក្ខម្មៈ ខ្ញុំមិនប្រាថ្នានូវគិហិភាពទេ ។ សម្លាញ់ទាំងនោះ ស្តាប់ពាក្យរបស់តថាគតបានហើយ ទៅជំរាបមាតាបិតា (នៃតថាគត) ឯមាតាបិតាបាននិយាយនឹងតថាគត យ៉ាងនេះថា ម្នាលព្រាហ្មណ៍ដ៏ចំរើន យើងទាំងអស់គ្នានឹងបួសដែរ មាតាបិតាទាំងគូនិងបងប្អូនប្រុសស្រីទាំង ៧ នាក់របស់តថាគត លះបង់ទ្រព្យរាប់មិនអស់ ចូលទៅកាន់ព្រៃ ធំជាមួយនិងតថាគត ។

ចប់ ភឹសចរិយា ទី ៤ ។

# សោណនន្ទបណ្ឌិតចរិយា ទី ៥

(២៥) មានចរិយាដទៃទៀត កាលតថាគតកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ដ៏ប្រសើរថ្លៃថ្លាក្នុងនគរព្រហ្មវឌ្ឍនៈ ។ កាលនោះឯង តថាគតបានឃើញសត្វលោក ដែលដល់នូវអន្ធភាព ត្រូវងងឹតគឺ អវិជ្ជាគ្របសង្កត់ ចិត្តរបស់តថាគត ក៏ខ្វល់ខ្វាយចាកភព ដូចជាហត្ថាជានេយ្យ ដែលគេចាក់នឹងជន្លួញដោយកម្លាំង ។ កាលនោះតថាគតឃើញបាបផ្សេងៗ ក៏គិតយ៉ាងនេះថា កាលណាហ្ន៎ អញនឹងបានចេញចាកផ្ទះ ចូលទៅកាន់ព្រៃ ។ គ្រានោះ ពួកញាតិអញ្ជើញតថាគត ដោយភោគៈគឺកាមទាំងឡាយ តថាគតប្រាប់នូវឆន្ទៈ (របស់ខ្លួន) ដល់ពួកញាតិទាំងនោះថា សូមអ្នកទាំងឡាយកុំអញ្ជើញខ្ញុំ ដោយកាមទាំងនោះឡើយ ។ ប្អូនប្រុសណា របស់តថាគតឈ្មោះនន្ទបណ្ឌិត ប្អូនប្រុសនោះ ក៏សិក្សាតាមតថាគត ពេញចិត្តនឹងបព្វជ្ជា ។ កាលនោះ តថាគតឈ្មោះ សោណៈ ប្អូននៃតថាគតឈ្មោះ នន្ទៈ និងមាតាបិតានៃ តថាគតទាំងពីរ លះបង់ភោគៈទាំងឡាយ ហើយចូលទៅកាន់ព្រៃធំក្នុង កាលនោះ ។

ចប់ សោណនន្ទបណ្ឌិតចរិយា ទី ៥ ។

# មូគផក្ខចរិយា ទី ៦

(២៦) មានចរិយាដទៃទៀត កាលដែលតថាគត កើតជារាជឱរស នៃព្រះបាទកាសិករាជ ជនទាំងឡាយមានមាតាបិតាជាដើម តែងហៅតថាគតថា មូគផក្ខៈផង ថាតេមិយៈផង ។ កាលនោះពួកស្រីស្នំ (របស់ព្រះបាទកាសិករាជ) ចំនួន ១៦.000 មិនមានកូនប្រុសអស់កាលកន្លងទៅនៃថ្ងៃនិងយប់ជាច្រើន គឺ អស់ច្រើនឆ្នាំ កើតបានតែរាជបុត្តមួយគឺតថាគត ។ ដោយបិតារបស់តថាគត បានដោយកម្រនូវតថាគតជាកូនជាទីស្រឡាញ់ ជាកូនមានជាតិខ្ពស់ទ្រទ្រង់សេចក្តីរុងរឿង ព្រះរាជាក៏យកនូវស្វេតច្ឆត្របាំងតថាគត ចិញ្ចឹមឱ្យផ្ទំលើសិរីសយនា ។ កាលនោះ តថាគតដេកលក់លើវរសយនាហើយ ភ្ញាក់ឡើង បានឃើញស្វេតច្ឆត្រគិតថា អញទៅនរក ព្រោះតែស្វេតច្ឆត្រណា សេចក្តីភ័យតក់ស្លុតកើតឡើង ដល់តថាគតជាមួយនឹងការឃើញនូវស្វេតច្ឆត្រនោះ ពេលនោះ តថាគតពិចារណាមើលថា ក្នុងកាលណាហ្ន៎ អញនឹងដោះខ្លួនឱ្យរួចពីស្វេតច្ឆត្រនេះ ។ ទេវតាជាសាលោហិតក្នុងកាលមុន ជាអ្នកប្រាថ្នាប្រយោជន៏ដល់តថាគត ទេវតានោះ បានឃើញតថាគតមានទុក្ខ ក៏ឱ្យតថាគតប្រកបក្នុងហេតុ ៣ ប្រការដូច្នេះ

ថា ចូរអ្នកកុំសំដែងនូវភាពរបស់ខ្លួនជាបណ្ឌិត ១ ចូរឱ្យសព្វសត្វទាំងឡាយ ដឹងថាអ្នកជាពាលវិញ ១ ឱ្យពួកជនទាំងពួង មើលងាយអ្នកវិញ ១ ប្រយោជន៍នឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ។ កាលទេវតានោះ ពោលយ៉ាងនេះហើយ តថាគតពោលនូវពាក្យនេះថា ម្នាលទេវតា អ្នកពោលនូវពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យនៃអ្នកនោះ ម្នាលទេវតាជាម៉ែ អ្នកឈ្មោះថា ប្រាថ្នានូវសេចក្តីចំរើន ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ។ លុះតថាគត ស្តាប់ពាក្យទេវតានោះហើយ ក៏បាននូវទួលគឺទីពឹង ដូចជាបុរស កាលលិចក្នុងសាគរ ហើយបាននូវទីទួល ។ តថាគតមានចិត្តត្រេកអរ មានចិត្តសង្វេគ បានអធិដ្ឋាននូវអង្គ ៣ យ៉ាង គឺអធិដ្ឋានជា គ ថ្លង់ និងខ្វិន វៀរចាកដំណើរធម្មតា ។ តថាគត អធិដ្ឋាននូវអង្គទាំង ៣ នុ៎ះហើយ នៅអស់ ១៦ ឆ្នាំ លំដាប់ពីនោះមក ជនទាំងឡាយច្របាច់ ដៃជើង អណ្តាត និងត្រចៀករបស់តថាគតមើល ឃើញថាអវយវៈ របស់តថាគត មិនខ្វះខាត ហើយតិះដៀលតថាគត ថាជាបុរស កាឡកណ្ណី ។ លំដាប់នោះ ពួកអ្នកជនបទទាំងអស់ មានសេនាបតី និងបុរោហិតជាប្រធាន ពួកជនទាំងអស់នោះ ស្រុះចិត្តគ្នា ត្រេកអរ ក្នុងការលះបង់ចោលតថាគត ។ លុះតថាគតស្តាប់នូវសេចក្តីយល់ឃើញរបស់ពួកជនទាំងនោះ ក៏មានចិត្ត

ត្រេកអរ មានចិត្តសង្វេគ តបះដែលតថាគតប្រព្រឹត្តហើយ ដើម្បីជាប្រយោជន៍ណា ប្រយោជន៍នោះ នឹងសម្រេចដល់តថាគតមិនខាន ។ ជនទាំងឡាយមានមាតា បិតាជាដើម ផ្ងូតទឹកក្រអូប លាបគ្រឿងក្រអូបហើយឱ្យពាក់រាជមកុដ អភិសេកដោយស្វេតច្ឆត្រ ធ្វើប្រទក្សិណបុរី ឱ្យតថាគតគ្រងរាជ្យអស់ ៧ ថ្ងៃ លុះមណ្ឌល ព្រះអាទិត្យរះឡើង សារថីនាំ តថាគតដោយរថចេញអំពីនគរ ចូលទៅកាន់ព្រៃ ។ សារថីបានទុករថ ក្នុងទីឱកាសមួយ ចងសេះផុត ពីដៃតថាគត ហើយជីករណ្ដៅដើម្បីកប់ តថាគតក្នុងផែនដី ។ តថាគត គ្រាន់តែគំរាមនូវអធិដ្ឋានដែលខ្លួន អធិដ្ឋានហើយ ដោយហេតុផ្សេងៗ តែមិនទំលាយនូវអធិដ្ឋាននោះទេ ព្រោះហេតុនៃពោធិញ្ញាណ ។ មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនក៏មិនមែនជា ទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះបានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ។ តថាគតអធិដ្ឋាននូវអង្គទាំង ៣ នុ៎ះ ហើយនៅអស់ ១៦ ឆ្នាំ អធិដ្ឋានដទៃស្មើដោយអធិដ្ឋាននេះមិនមានឡើយ នេះជាអធិដ្ឋានបារមីរបស់តថាគត ។

ចប់ មូគផក្ខចរិយា ទី ៦ ។

## កបិលរាជចរិយា ទី ៧

(២៧) កាលដែលតថាគតកើតជាស្ដេចស្វា សម្រេចទីលំនៅជិត ឆ្នេរនៃស្ទឹងមួយ កាលនោះ តថាគតត្រូវក្រពើបៀតបៀនហើយ មិនបាននូវដំណើរចេញទៅ ។ តថាគតឋិតនៅលើខ្នងថ្មណា ដែលតាំងនៅក្នុងស្ទឹង ក៏បានលោតអំពីត្រើយអាយទៅកាន់ត្រើយនាយ ហើយទំលើខ្នងថ្មនោះ ដែលមានក្រពើនៅ ជាសត្រូវឃើញគួរខ្លាច ។ ក្រពើនោះ និយាយនឹងតថាគតថា អ្នកចូរមកវិញ តថាគតនិយាយ តបនឹងក្រពើនោះថា អើខ្ញុំនឹងមកវិញ ហើយតថាគតលោតជាន់លើ ក្បាលក្រពើនោះ ទៅឋិតនៅលើត្រើយនាយវិញ ។ តថាគតពោលនូវពាក្យសត្យ មិនពោលពាក្យមុសាវាទ ដល់ក្រពើនោះ កុសលធម៌ដទៃ ស្មើរនឹងសច្ចៈរបស់តថាគតមិនមានឡើយ នេះជាសច្ចបារមីរបស់តថាគត។

ចប់ កបិលរាជចរិយា ទី ៧ ។

## សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨

(២៨) មានចរិយាដទៃទៀត កាលដែលតថាគតជាតាបសឈ្មោះសច្ចៈ តថាគតបានរក្សាសត្វលោក ដោយសច្ចៈ ធ្វើមហាជនឱ្យព្រមព្រៀងគ្នា ។

ចប់ សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨ ។

# វដ្ដកបោតកចរិយា ទី ៩

(២៩) ចរិយាដទៃទៀត កាលដែលតថាគតកើតជាកូនសត្វក្រួច ក្នុងអរញ្ញប្រទេសមួយ ទៀបដែនមគធៈ ជាសត្វតូចដូចជាដុំសាច់ មិនទាន់ដុះស្លាបនៅក្នុងសំបុក ។ កាលនោះ មាតា(របស់តថាគត) នាំយក(ចំណី)ដោយចំពុះមកចិញ្ចឹមតថាគត តថាគតរស់នៅដោយសារសម្ផស្សរបស់មាតានោះ តថាគតមិនទាន់មានកម្លាំងកាយនៅឡើយ ។ ភ្លើងព្រៃ ឆេះព្រៃក្នុងគិម្ហសម័យ រាល់៧ឆ្នាំ អណ្ដាតភ្លើង ក៏រាលចូលមកជិតលំនៅនៃតថាគត ។ អណ្ដាតភ្លើងដ៏ធំកាលធ្វើសម្លេងថា ធុំធុំ យ៉ាងនេះ ភ្លើងនោះ ឆេះរាលចូលមករកតថាគតជាលំដាប់ ។ មាតាបិតាតថាគត ភ័យតក់ស្លុតព្រោះខ្លាចសន្ទុះភ្លើង ក៏លះបង់ចោលតថាគតក្នុងសំបុក ហើយដោះខ្លួនចេញរួចទៅ ។ តថាគតលះបង់នូវជើងនិងស្លាប តថាគតមិនមានកម្លាំងកាយ តថាគតជាសត្វមិនមានដំណើរទៅក្នុងទីនោះ កាលណោះគិតយ៉ាងនេះថា អញភ័យតក់ស្លុតញាប់ញ័រ ស្ទុះទៅរកមាតាបិតាណាបើមាតាបិតាទាំងនោះ លះបង់អញចេញ ទៅហើយ តើក្នុងថ្ងៃនេះ

អញត្រូវធ្វើដូចម្ដេច ។ ព្រះសព្វញ្ញុពុទ្ធប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ (សេចក្ដីស្អាត) និងសេចក្ដីអាណិតសឹងមានក្នុងលោក (បើដូច្នោះ) អញនឹងធ្វើនូវសច្ចកិរិយាដ៏ឧត្ដមដោយសច្ចៈនោះ ។ តថាគតពិចារណា កម្លាំងធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌(នោះ)ថា ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនរួច ជើងទាំងឡាយ របស់ខ្ញុំមាន តែដើរមិនបាន មាតាបិតា(របស់ខ្ញុំចេញ)បាត់ទៅហើយ ម្នាលភ្លើងព្រៃអ្នកចូរចៀសចេញទៅ ។ ព្រោះសច្ចកិរិយា ដែលតថាគត បានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចំងាយ ១៦ ករីសៈ (ហើយរលត់ក្នុងទីនោះ) ដូចជាគប់ភ្លើងដែលបុគ្គល ជ្រលក់ទៅក្នុងទឹក កុសលធម៌ដទៃ ស្មើនឹងសច្ចៈនៃតថាគតពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ វដ្ដកបោតកចរិយា ទី ៩ ។

# មច្ឆរាជចរិយា ទី ១០

(៣០) មានចរិយាដទៃទៀត កាលដែលតថាគត កើតជាស្តេចត្រី នៅក្នុងមហាស្រះ លុះដល់គិម្ហសម័យ ដែលមានកំដៅព្រះអាទិត្យយ៉ាងខ្លាំង ទឹកក្នុងស្រះក៏រីងហួតអស់ ។ លំដាប់នោះ ក្អែក ត្មាត ខ្លែងក្រហម ខ្លែងខ្មៅ និងខ្លែងធំ ចុះទៅទំ (លើភក់) ស៊ីនូវត្រីទាំងឡាយ ទាំងយប់ទាំងថ្ងៃ ។ តថាគតព្រមទាំងពួកញាតិ ត្រូវពួកសត្វ មានក្អែកជាដើមបៀតបៀនក្នុងទីនោះហើយ ក៏គិតយ៉ាងនេះថា ញាតិទាំងឡាយ (របស់អញ) នឹងរួចចាកទុក្ខដោយឧបាយដូចម្តេចហ្ន៎ ។ តថាគតគិតនូវធម៌និងអត្ថ ហើយបានឃើញសច្ចៈ កាលឃើញហើយ ឋិតនៅក្នុងសច្ចៈនោះ ដោះញាតិឱ្យរួចចាកវិនាសធំទៅបាន ។ តថាគត រឭកនូវធម៌របស់សប្បុរសទាំងឡាយ ហើយពិចារណានូវបរមត្ថសច្ចៈ ធ្វើនូវសច្ចកិរិយា ដែលជាធម្មជាតិទៀងទាត់ក្នុងលោកថា តថាគតរឭកឃើញនូវខ្លួន ក្នុងកាល

ណា តថាគតបានដល់នូវភាពជាអ្នកដឹងក្តី ក្នុងកាលណា ក្នុងកាលនោះ តថាគតមិនដែលក្លែងបៀតបៀន សូម្បីនូវសត្វណាមួយឡើយ ។ ដោយពាក្យសច្ចៈនេះ សូមឱ្យមេឃបង្អុរភ្លៀងចុះ ម្នាលមេឃ ចូរអ្នកបង្អុរភ្លៀងចុះមក ចូរអ្នកញ៉ាំងកំណប់ទ្រព្យរបស់ ក្អែកឱ្យវិនាសអស់ទៅ ។ ចូរអ្នកញ៉ាំងពួកក្អែកឱ្យសោយសោក ចូរអ្នក ញ៉ាំងពួកត្រីឱ្យរួចចាកសោក ។ មេឃក៏បង្អុរភ្លៀងចុះមក ដំណាលនឹងពាក្យសច្ចៈដ៏ប្រសើរ ដែលតថាគតធ្វើហើយ ។ តថាគតធ្វើនូវសច្ចៈដ៏ប្រសើរមានសភាពយ៉ាងនេះ ឱ្យជាព្យាយាមដ៏ឧត្តម ភ្លៀងក៏ធ្លាក់ចុះមកបំពេញនូវទីទួល ទីទាបមួយរំពេច ។ តថាគត អាស្រ័យកម្លាំងតេជៈនៃសច្ចៈ បានញ៉ាំងមហាមេឃឱ្យបង្អុរភ្លៀង គុណធម៌ដទៃទៀតស្មើនឹងសច្ចៈនៃតថាគតពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ មច្ឆរាជចរិយា ទី ១០ ។

# កណ្ហទីបាយនចរិយា ទី ១១

(៣១) មានចរិយាដទៃទៀត កាលតថាគតជាឥសី ឈ្មោះកណ្ហទីបាយនៈ អផ្សុកហើយ នៅតែប្រព្រឹត្តព្រហ្មចរិយៈ អស់ ៥០ ឆ្នាំប្លាយ ។ អ្នកណាមួយ មិនដឹងនូវសេចក្តីអផ្សុកក្នុងចិត្តរបស់តថាគតនុ៎ះទេ ទាំងតថាគតសោត ក៏មិនប្រាប់នូវសេចក្តីមិនត្រេកអរ និងសេចក្តីត្រេកអរក្នុងចិត្ត ដល់អ្នកណាមួយឡើយ ។ មហាឥសីឈ្មោះមេណ្ឌព្យៈ អ្នកប្រព្រឹត្តដ៏ប្រសើរស្មើគ្នា ជាសម្លាញ់របស់តថាគតប្រកបដោយបុញ្ញកម្ម ហើយបាននូវការឡើងកាន់ដែកស្រួច ។ តថាគតថែទាំមណ្ឌព្យៈ តាបសនោះ រហូតបានដល់នូវភាព ជាបុគ្គលជារោគ ហើយលាមកកាន់អាស្រមនៃខ្លួន របស់តថាគតវិញ ។ ព្រាហ្មណ៍ជាសម្លាញ់ នាំប្រពន្ធនិងកូនមក ជនទាំង ៣ នាក់ ជួបជុំគ្នាចូលទៅកាន់ទីដែលភ្ញៀវមកហើយ ។ តថាគតអង្គុយក្នុងអាស្រមរបស់ខ្លួន សំណេះសំណាលជាមួយនឹងជនទាំងនោះ ឯទារកបោះកូនឃ្លីលេង បានញ៉ាំងអាសិរពិសឱ្យខឹង ។ លំដាប់នោះ កុមារនោះស្វែងរកផ្លូវដែលកូនឃ្លីនោះរមៀល ក៏យកដៃស្ទាបត្រូវក្បាលអាសិរពិស ។ ឯពស់នោះក៏ខឹងនឹងការស្ទាបត្រូវនៃទារកនោះ អាស្រ័យកម្លាំងនៃ

ពិសកំរើក ក៏ចឹកទារកក្នុងខណៈនោះ ដោយសេចក្តីក្រោធយ៉ាងខ្លាំង ។ ទារកដែលត្រូវពស់ចឹកហើយក៏ដួល លើផែនដី ដោយពិសដ៏ខ្លាំងមួយរំពេច ព្រោះហេតុនោះ បានជាតថាគតមានទុក្ខ ទុក្ខនោះផ្សាយមកដល់តថាគត ។ តថាគតលួងលោមជនទាំងនោះ ដែលដល់នូវសេចក្តីទុក្ខ មានសរគឺសេចក្តីសោក បានធ្វើនូវសច្ចកិរិយា ដ៏ថ្លៃថ្លាប្រសើរ ឧត្តមជាដំបូងថា តថាគតមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្មចរិយៈអស់ ៧ ថ្ងៃ លំដាប់តទៅ តថាគតប្រាប់ព្រហ្មចរិយៈណា អស់ ៥០ ឆ្នាំប្លាយ ។ តថាគតប្រព្រឹត្តព្រហ្មចរិយៈនោះទាំងអផ្សុក ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរសាបសូន្យទៅ យញ្ញទត្តកុមារចូររស់ឡើង ។ យញ្ញទត្តមាណព ដែលញាប់ញ័រដោយកម្លាំងនៃពិសមិនដឹងខ្លួនសោះ ស្រាប់តែក្រោកឡើងរួច ទាំងជាបុគ្គលសះស្បើយរោគ ដំណាលនឹងពាក្យដែលតថាគតធ្វើហើយ គុណធមិដទៃទេស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ កណ្ហទីបាយនចរិយា ទី ១១។

## សុតសោមចរិយា ទី ១២

(៣២) មានចរិយាដទៃទៀត កាលដែលតថាគត ឈ្មោះ សុតសោម ជាម្ចាស់ផែនដី ត្រូវស្ដេចបោរិសាទចាប់ តថាគត ក៏បាននឹក ឃើញពាក្យប្ដេជ្ញា ដែលខ្លួនបានធ្វើ ចំពោះនន្ទព្រាហ្មណ៍ ។ ស្ដេចបោរិសាទ ដោតក្សត្រ ១០១ អង្គត្រង់បាតដៃ ហើយញុាំង ស្ដេចទាំងនោះ ឱ្យស្វិតស្រពោន ហើយចូលទៅនាំយកតថាគតក្នុង ពេលសម្រេចយ័ញ្ញ ។ ស្ដេចបោរិសាទ សួរតថាគតថា អ្នកឯងចង់រួច ខ្លួន (អំពីដៃយើង)ឬទេ បើអ្នកអាចត្រឡប់មក (កាន់សំណាក់) យើងវិញ យើងនឹងព្រមធ្វើតាមសេចក្ដីពេញចិត្តរបស់អ្នក ។ កាល នោះ តថាគតទទួល(ពាក្យ) ស្ដេចបោរិសាទនោះហើយ ចូលទៅកាន់ បុរីជាទីរីករាយ ប្រគល់រាជ(ដល់មាតាបិតា) នឹងបាច់និយាយថ្វីដល់ ការត្រឡប់មកនៃតថាគតវិញ ។ តថាគតរឭកនូវធម៌ របស់សប្បុរស ទាំងឡាយ ដែលព្រះជិនស្រីទាំងឡាយ ធ្លាប់សេពក្នុងកាលមុន ឱ្យទ្រព្យដល់ព្រាហ្មណ៍ ហើយចូលទៅកាន់ស្ដេចបោរិសាទ ។ តថាគត មិនមានសេចក្ដីសង្ស័យថា ស្ដេចបោរិសាទនេះ នឹងសម្លាប់ឬមិន សម្លាប់នូវអញក្នុងទីនោះឡើយ តថាគតរក្សាពាក្យសច្ចៈ ចូលទៅ

(កាន់សំណាក់បោរិសាទ) ដើម្បីលះបង់នូវជីវិត គុណធម៌ដទៃទៀតស្មើនឹងសច្ចៈនៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ សុតសោមចរិយា ទី ១២ ។

## សុវណ្ណសាមចរិយា ទី ១៣

(៣៣) កាលដែលតថាគត កើតជាតាបសឈ្មោះ សាមៈ នៅក្នុងអាស្រម ដែលព្រះឥន្ទ្រនិម្មិតឱ្យក្នុងព្រៃ តថាគតញុំាងសីហៈ និង ខ្លាធំទាំងឡាយក្នុងព្រៃ ឱ្យចូលមកជិតដោយមេត្តាបាន ។ សត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ក្របី ក្តាន់ នឹងជ្រូកព្រៃមកចោមរោមតថាគត ដែលនៅក្នុងព្រៃ ។ សត្វណាមួយ មិនធ្វើតថាគតឱ្យតក់ស្លុតទេ ទាំងតថាគត ក៏មិនខ្លាចសត្វណាមួយឡើយ កាលនោះ កម្លាំងមេត្តា ឧបត្ថម្ភតថាគតឱ្យតថាគតនៅក្នុងព្រៃ ដោយសួស្តី ។

ចប់ សុវណ្ណសាមចរិយា ទី ១៣ ។

# ឯករាជចរិយា ទី ១៤

(៣៤) មានចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេច ឈ្មោះឯករាជ បានអធិដ្ឋានសីលដ៏ក្រៃលែង ហើយគ្រប់គ្រងមហាប្រថពី ក្នុងកាសិករដ្ឋ ។ តថាគតបានប្រព្រឹត្តកុសលកម្មបថ ១០ ឥតមានសេសសល់ សង្គ្រោះមហាជនដោយសង្គហវត្ថុទាំង ៤ ។ តថាគត មិនប្រមាទក្នុងលោកនេះ និងបរលោកយ៉ាងនេះ វេលានោះស្តេចក្នុងដែនកោសលឈ្មោះ ទព្វសេន ចូលមកដណ្តើមរាជបុរីរបស់តថាគត ។ ស្តេចទព្វសេន ធ្វើនូវអ្នកនិគមព្រមទាំងពួកពល និងអ្នកជនបទ ដែលរស់នៅព្រោះអាស្រ័យស្តេចទាំងអស់ ឱ្យតាំងនៅក្នុងដៃ ហើយជីកកប់តថាគតក្នុងរណ្តៅ ។ តថាគតបានឃើញនូវមណ្ឌលនៃអាមាត្យ រាជ្យនិងវាំងដ៏ស្តុកស្តម្ភរបស់តថាគត ដូចកូនជាទីស្រឡាញ់ ដែលត្រូវស្តេចទព្វសេន ដណ្តើមយកហើយ (ក៏ផ្សាយមេត្តាចំពោះស្តេច ទព្វសេននោះ) គុណធម៌ដទៃស្មើនឹងមេត្តានៃតថាគតពុំមានឡើយ នេះជាមេត្តាបារមីរបស់តថាគត ។

ចប់ ឯករាជចរិយា ទី ១៤ ។

# មហាលោមហំសចរិយា ទី ១៥

(៣៥) តថាគតសម្រេចសេយ្យាសន៍ គើយឆ្អឹងសាកសពក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត (តថាគត) ហើយសំដែងនូវប្រការដ៏ប្លែកច្រើនយ៉ាង ។ ពួកក្មេងដទៃ ជាអ្នកដឹងការណ៍ (ឃើញទារកទាំងឡាយ) ក៏សប្បាយរីករាយ មានចិត្តសង្វេគទៅនាំយកគ្រឿងក្រអូប ផ្កាកំរង ភោជនផ្សេងៗដ៏ច្រើន និងគ្រឿងបណ្ណាការមកឱ្យតថាគត ។ ពួកក្មេងអ្នកស្រុកណា នាំយកសេចក្ដីទុក្ខមកឱ្យតថាគត ពួកក្មេងអ្នកស្រុកណា នាំសេចក្ដីសុខដល់តថាគត តថាគតមានចិត្តស្មើចំពោះទារកទាំងនោះ មិនអាណិតមិនក្រោធ ។ តថាគតមានចិត្តជាកណ្ដាល ក្នុងសុខនិងទុក្ខ ក្នុងយសនិងអយស តថាគតមានចិត្តស្មើក្នុងលោកធម៌ទាំងពួង នេះជាឧបេក្ខាបារមីរបស់តថាគត ។

ចប់ មហាលោមហំសចរិយា ទី ១៥ ។

# ឧទ្ទាននៃចរិយានោះ

យុធញ្ជយចរិយា ១ សោមនស្សចរិយា ១ អយោឃរចរិយា ១ ភីសចរិយា ១ សោណនន្ទបណ្ឌិតចរិយា ១ មូគផក្ខចរិយា ១ កបិលរាជចរិយា ១ សច្ចវ្ហយបណ្ឌិតចរិយា ១ វដ្ដបោតកចរិយា ១ មច្ឆរាជចរិយា ១ កណ្ហទីបាយនចរិយា ១ សុតសោមចរិយា ១ សុវណ្ណសាមចរិយា ១ ឯករាជចរិយា ១ លោមហំសចរិយា ១ ព្រះមហេសីសម្ពុទ្ធ ទ្រង់សំដែងហើយ ដោយប្រការដូច្នេះ ។ តថាគតរងទុក្ខច្រើនប្រការ សោយសម្បត្តិច្រើនប្រការ ក្នុងភពតូច ភពធំ ដូចបានរៀបរាប់មកយ៉ាងនេះ ហើយបានសម្រេចនូវសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតបានឱ្យទាន ដែលព្រះពោធិសត្វគប្បីឱ្យ ទាំងបំពេញសីលមិនមានសេសសល់ ហើយចេញទៅកាន់មហាភិនិក្ខមន៍ បានដល់បារមី សម្រេចនូវសម្ពោធិញ្ញាណ ជាញាណដ៏ឧត្តម ។ តថាគត បានសាកសួរបណ្ឌិតទាំងឡាយ បានធ្វើព្យាយាមដ៏ឧត្តម បានដល់ខន្តិបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតបាន ធ្វើអធិដ្ឋានយ៉ាងមាំ បានរក្សាសច្ចៈ បានដល់មេត្តាបារមី ហើយសម្រេច សម្ពោធិញ្ញាណដ៏ឧត្តម ។ តថាគតមានចិត្តស្មើក្នុង

លោកធម៌ គឺលាភ អលាភ យស អយស សេចក្តីរាប់អាននិងសេចក្តីមើលងាយ ហើយបានសម្រេច សម្មោធិញ្ញាណដ៏ឧត្តម ។ អ្នកទាំងឡាយគួរឃើញនូវកោសជ្ជៈ ថាជាភ័យ គួរឃើញនូវការប្រារព្ធព្យាយាម ថាជាសេចក្តីក្សេម ហើយប្រឹងប្រែងព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ អ្នកទាំងឡាយគួរឃើញនូវការទាស់ទែង ថាជាភ័យ គួរឃើញការមិនទាស់ទែង ថាជាសេចក្តីក្សេម ហើយចូរព្រមព្រៀងគ្នា ទាំងជាបុគ្គល មានពាក្យពីរោះរកគ្នាចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ មួយទៀត អ្នកទាំងឡាយ គួរឃើញនូវសេចក្តីប្រមាទ ថាជាភ័យ គួរឃើញសេចក្តីមិនប្រមាទ ថាជាសេចក្តីក្សេម ហើយចូរចំរើនមគ្គ ប្រកបដោយអង្គ ៨ ចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរនូវបុព្វចរិយារបស់ព្រះអង្គ ហើយសំដែង នូវធម្មបរិយាយ ឈ្មោះពុទ្ធាបទាន ដោយប្រការដូច្នេះ ។

ចប់ ចរិយាបិដក ។

# សមោធានកថា

(៣៦) បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០, បារមីទាំងនេះ ជាគ្រឿងញ៉ាំងពោធិញ្ញាណ ឱ្យបានសម្រេច គឺព្រះបាទសិវិរាជដ៏ប្រសើរ បានបំពេញទានបារមី ព្រះបាទវេស្សន្តរ និងវេលាមព្រាហ្មណ៍ បានបំពេញទានឧបបារមី អកិត្តិតាបសបានបំពេញទានដ៏មានកម្លាំង ហៅថាទានឧបបារមី កាលតថាគតកើតជាមាន់និងទន្សាយដ៏ប្រសើរ បានបំពេញទានបរមត្ថបារមី ។ កាលតថាគតកើតជាស្ដេចស្វាក្ដី ជាដំរីឆទ្ទន្តក្ដី ជាដំរីចិញ្ចឹមមាតាក្ដី បានបំពេញសីលបារមី ពាក្យដូច្នេះនេះ ព្រះមហេសីទ្រង់សំដែងហើយ ។ កាលតថាគតកើតជាស្ដេចនាគ ឈ្មោះចម្បេយ្យ និងជាស្ដេចនាគឈ្មោះភូរិទត្ត បានបំពេញសីលឧបបារមី កាលតថាគតកើតជាសង្ខបាលនាគរាជជាអ្នកប្រាជ្ញ បានបំពេញសីលបរមត្ថបារមី ។ កាលតថាគត កើតជារាជបុត្ត ឈ្មោះយុធញ្ជ័យក្ដី ជាមហាគោវិន្ទក្ដី ជាហត្ថិបាលក្ដី ជាកូនព្រាហ្មណ៍មហាសាល ឈ្មោះអយោឃរៈក្ដី ជាភល្លាតិយៈក្ដី ជាសុវណ្ណសាមក្ដី ជាមឃទេវបុត្តក្ដី ជានេមិរាជក្ដី បានបំពេញ

ទានឧបបារមី ។ កាលតថាគតកើតជាមហោសថបណ្ឌិតក្តី ធនរដ្ឋ-បណ្ឌិតក្តី កុណ្ឌកបណ្ឌិតក្តី តណ្ឌិលបណ្ឌិតក្តី តិត្តិរៈក្តី សកុណៈក្តីនុ៎ះ បានបំពេញបញ្ញាឧបបារមី ។ កាលតថាគត កើតជាវិធុរបណ្ឌិតក្តី ជាសម្ភវកុមារក្តី ទាំងពីរនុ៎ះ បានបំពេញបញ្ញាបារមី កាលតថាគត កើតជាសុរិយព្រាហ្មណ៍ក្តី ជាមាតង្គបណ្ឌិតក្តី ដែលជាសិស្សអាស្រ័យនូវអាចារ្យ ក្នុងកាលមុន ក៏បានបំពេញនូវបញ្ញាបារមីដែរ ។ ឯបញ្ញាបរមត្ថបារមីនុ៎ះឯង (តថាគតបានបំពេញ ក្នុងកាលយោនយកកំណើតកើត) ជា សេនកបណ្ឌិត កាលតថាគត កើតប្រាកដជាស្តេចជនកមានសីល មានព្យាយាម មានការប្រឹងប្រែងយ៉ាងមាំ បានបំពេញវីរិយបរមត្ថបារមី កាលតថាគត កើតជាស្តេចស្វា ជាអ្នកគោរពធម៌ ៥ ប្រការ បានបំពេញវីរិយបារមី ។ កាលតថាគតកើតជាធម្មបាលកុមារ បានបំពេញខន្តិបារមី ជាគ្រឿងញ៉ាំញីដោយធម៌នូវបុគ្គលមិនប្រកបដោយធម៌ ហៅថា ខន្តិឧបបារមី ។ កាលតថាគតកើតជាខន្តិវាទីតាបស ស្វែងរកពុទ្ធភូមិ តថាគតបានធ្វើ នូវអំពើដ៏កម្រ ជាច្រើនយ៉ាង ដើម្បីបំពេញ នូវខន្តិបរមត្ថបារមី ដោយខន្តិវាទ ។

កាលតថាគតកើតជាទន្សាយ និងជាសត្វក្រួច អាស្រ័យនូវគុណគឺសច្ចៈ ដូចមានខាងលើនោះ បានញុំាងភ្លើងឱ្យរលត់ដោយសច្ចៈនេះក៏ជាសច្ចបារមី ។ កាលតថាគត កើតជាត្រី នៅក្នុងទឹកបានធ្វើនូវសច្ចៈដ៏ឧត្តមញុំាមហាមេឃឱ្យបង្អុរចុះ នេះជាសច្ចបារមីរបស់តថាគត ។ កាលតថាគតកើតជាសុបារបណ្ឌិត ជាអ្នកប្រាជ្ញ បានញុំាងទូកឱ្យឆ្លងដោយសច្ចៈ កាលកើតជាឥសី ឈ្មោះកណ្ហទីបាយនៈ បានញុំាងពិសឱ្យសាបរលាបដោយសច្ចៈ កាលកើតជាស្វា បានឆ្លងខ្សែទឹកគង្គាដោយសច្ចៈ នេះជាបារមី របស់តថាគតជាសាស្តា ក្នុងកាលនោះ បារមីនោះជាសច្ចៈឧបបារមី ។ កាលតថាគតកើតជាស្តេចឈ្មោះសុតសោមរក្សាសច្ចៈដ៏ឧត្តម ដោះក្សត្រ ១០១ អង្គឱ្យរួច (នេះ)ជាសច្ចបរមត្ថបារមី ។ កាលតថាគតកើតជាកឹឆន្ទៈ កាលនោះ មានបារមីដោយការអធិដ្ឋាន កាលកើតជាទុកៈនិងមាតង្គយៈបានបំពេញអធិដ្ឋានឧបបារមី ។ កាលតថាគត កើតជាមូគផក្ខពោធិសត្វ បានបំពេញអធិដ្ឋានបរមត្ថ-បារមី កាលកើតជាមហាកណ្ហៈ ប្រព្រឹត្តទៅដោយមេត្តា កាលកើតជារាជសោធនៈ (ក៏ប្រព្រឹត្តទៅ) ដោយមេត្តានោះដែរ បារមីទាំងពីរ

នេះ ហៅថាមេត្តាបារមី ។ កាលតថាគត កើតជាស្តេចព្រហ្មទត្ត (ប្រព្រឹត្តទៅ) ដោយសីល កាលកើតជាគណ្ឋិតិណ្ឌកៈ នេះ(ក៏បាន ប្រព្រឹត្តទៅ) ដោយសីលដែរ។ កាលតថាគតកើតជានន្ទៈ បានធ្វើនូវ សេចក្តីស្រឡាញ់ (ក្នុងសព្វញ្ញុតញ្ញាណ) បារមីទាំងនោះ ជាឧបបារមី ឯបរមត្ថបារមី បានបំពេញហើយ ក្នុងកាលតថាគតកើតជាស្តេច ឯករាជ បារមីដទៃប្រាកដស្មើ ដោយមេត្តាបារមីនេះ ពុំមានឡើយ ។ កាលតថាគតកើតជាសេកទាំងពីរ បានបំពេញឧបបារមី កាលកើតជា លោមហំសនៈ បានបំពេញបរមត្ថបារមី ឯបារមី ១០ របស់តថាគត នេះ ជាចំណែកនៃពោធិញ្ញាណដ៏ប្រសើរ ។ បារមីទាំងឡាយមិន លើសអំពី ១០ មិនខ្វះអំពី ១០ បារមីទាំងអស់ពេញត្រឹម ១០ មិនខ្វះ មិនលើស ។

ចប់ សមោធានកថា

ចប់ ចរិយាបិដក ។

# ប្រភេទនៃទុក្ករកិរិយា

(៣៧) នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះមានតែអាត្មាអញ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន(ក្រអូមមាត់) ដោយអណ្តាត សង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ។ នែអគ្គិវេស្សនៈ តថាគតនោះ ក៏ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន ដោយអណ្តាត សង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត នែអគ្គិវេស្សនៈ កាលដែលតថាគតនោះ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន ដោយអណ្តាត សង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង ។ នែអគ្គិវេស្សនៈ ដូចបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាងខ្លួន ត្រង់ក្បាលផង ចាប់ត្រង់កផង គប្បីសង្កត់គាបផ្ចប់ មានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ កាលដែលតថាគតខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន ដោយអណ្តាតសង្កត់គាបផ្ចប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង មានឧបមេយ្យយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់មិនធូរថយ សតិក៏តាំងកល់ខ្ជាប់

មិនមានវង្វេងភ្លេច តែចំណែកខាងកាយ របស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្ដីព្យាយាម ដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណា ជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ នូវចិត្តរបស់តថាគតបានឡើយ ។

(៣៨) នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា បើដូច្នោះមានតែអាត្មាអញពិចារណានូវអប្បាណកជ្ឈានគឺឈានដែលគ្មានដង្ហើមចេញចូល ។ នែអគ្គិវេស្សនៈ តថាគតបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង ។ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សម្លេងរបស់ខ្យល់ ដែលចេញមកអំពីរន្ធត្រចៀកទាំងសងខាង ក៏ឮខ្លាំងក្រៃពេក ។ សម្លេងស្នប់របស់ជាងមាស ដែលកំពុងសប់លាន់ឮខ្លាំង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សម្លេងរបស់ខ្យល់ ដែលចេញមកអំពីរន្ធត្រចៀកទាំងសងខាងក៏លាន់ឮខ្លាំង យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្ដី

ព្យាយាមរបស់តថាគត តឹងតែងណាស់ មិនបន្ធូរបន្ថយ ទាំងសតិក៏តាំងកល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោតហើយ ទៅជាកាយក្រវល់ក្រវាយមិនបានស្ងប់រម្ងាប់ដោយសារសេចក្តី ព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

(៣៩) នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះគួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិង ខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំង ចាក់ឆ្មៀលនូវក្បាល ដោយចុងដែកស្រួចដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ហើយខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់

ដោតនូវក្បាល យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្ដីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ សតិក៏តាំកល់ខ្ជាប់មិនបានវង្វេងភ្លេចឡើយ តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្ដីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជា ទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ នូវចិត្តរបស់តថាគតបានឡើយ ។

(៤០) នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈានតែម្យ៉ាង ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែង ក៏កើតប្រាកដក្នុងក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំងរុំក្បាល ដោយកំណាត់ព្រ័ត្រដ៏មាំ យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល

អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែង ក៏កើតប្រាកដក្នុងក្បាល ក៏យ៉ាងនោះឯង ។ នៃអគ្គិវេស្សនៈ សេចក្ដីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តាំងខ្ជាប់ មិនបានវង្វេងភ្លេចឡើយ តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារ សេចក្ដីព្យាយាមដ៏លំបាកនោះឯង ។ នៃអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏គ្របសង្កត់ចិត្តរបស់តថាគតមិនបានឡើយ ។

(៤១) នៃអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ នៃអគ្គិវេស្សនៈ តថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នៃអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតឆ្អលផ្ទៃ។ នៃអគ្គិវេស្សនៈ បុរសអ្នកសម្លាប់គោ ឬកូនសិស្ស

នៃបុរសអ្នក សម្លាប់គោដ៏ឈ្លាសវៃ គប្បីអារនូវផ្ទៃដោយកំបិតសំរាប់អារគោដ៏មុត យ៉ាងណាមិញ នៃអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញនិង ខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតឆ្លុលនូវផ្ទៃយ៉ាងនោះឯង ។ នៃអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តាំងកល់ខ្ជាប់មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នៃអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

(៤២) ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញនិងខ្យល់

ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ ។ ម្នាលអគ្គិវេស្សនៈ បុរសមានកម្លាំងពីរនាក់ ចាប់នូវបុរសមានកម្លាំងថយជាងខ្លួន ត្រង់ដៃទាំងសងខាង ឆ្អើរកំដៅលើរណ្តៅរងើកភ្លើងយ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយយ៉ាងនោះឯង ។ ម្នាលអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តំកល់ខ្ជាប់ខ្ជួន មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតឡើយ ។ ម្នាលអគ្គិវេស្សនៈ មានពួកទេវតាបានឃើញតថាគតដូច្នោះហើយ និយាយយ៉ាងនេះថា ព្រះសមណគោតមធ្វើមរណកាលហើយ ។ ទេវតាពួកខ្លះនិយាយយ៉ាង

នេះថា ព្រះសមណគោតម មិនទាន់ធ្វើមរណកាលនៅឡើយទេ តែគង់នឹងធ្វើមរណកាលពុំខាន ។ ទេវតាពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតម មិនបានធ្វើមរណកាលទៅហើយទេ ទាំងនឹងមិនធ្វើមរណកាលឡើយ ព្រះសមណគោតមជាអរហន្ត ទ្រង់គង់ព្រះជន្មាយុដោយពិត ការគង់ព្រះជន្មាយុរបស់ព្រះអរហន្តនោះ មានសភាពយ៉ាងនេះ ។

(៤៣) ម្នាលអគ្គិវេស្សនៈ តថាគតមានសេចក្តីត្រិះរិះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិ ដើម្បីផ្តាច់បង់នូវអាហារដោយប្រការទាំងពួង ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង ពួកទេវតាចូលទៅរកតថាគត ហើយនិយាយដូច្នេះថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះអង្គកុំប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងឡើយ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ បើព្រះអង្គនឹងប្រតិបត្តិ ដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងតទៅ យើងទាំងឡាយនឹងញ៉ាំងឱជាទិព្វ ឱ្យជ្រួតជ្រាបទៅតាមរណ្តៅរោមទាំងឡាយ របស់ព្រះអង្គៗ នឹងរស់នៅ ដោយឱជាទិព្វនោះបាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើអាត្មាអញនឹងប្តេជ្ញាថា ខ្លួនជា

អ្នកគ្មានភោជនដោយប្រការទាំងពួងផង ទេវតាទាំងឡាយនេះ នឹងញ៉ាំងឱជាទិព្វឱ្យជ្រួតជ្រាបចូលទៅ តាមរណ្ដៅរោមទាំងឡាយ របស់អាត្មាអញផង អាត្មាអញនឹងរស់នៅដោយឱជាទិព្វនោះផង អំពើនោះជាអំពើកុហករបស់អាត្មាអញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏និយាយឃាត់ទេវតាទាំងនោះវិញ តថាគតប្រាប់ថាកុំឡើយ ដូច្នេះ ។

(៤៤) ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ បរិភោគនូវអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដីត្រឹមតែមួយទូកដៃ១ ។ ម្នាលអគ្គិវេស្សនៈ តថាគតក៏បានបរិភោគ នូវអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ត្រឹមតែមួយទូកដៃ១ ។ ម្នាលអគ្គិវេស្សនៈ កាលដែលតថាគតនោះ បរិភោគអាហារបន្តិច១ ទោះបីគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយ-ជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ត្រឹមតែមួយទូកដៃ១ កាយរបស់តថាគតក៏ដល់ នូវអាការស្គាំងស្គមក្រៃលែង ។

អវយវៈតូច ធំរបស់តថាគត ដូចជាថ្នាំងនៃវល្លិ ឈ្មោះអសីតិកៈ ឬដូចជាថ្នាំងនៃ វល្លិប្រេង ព្រោះមានអាហារតិចនោះឯង ។ គគូថរបស់តថាគត ដូចជាស្នាមជើងនៃសត្វឱដ្ឋ ព្រោះមានអាហារតិចនោះឯង ។ ឆ្អឹងខ្នងរបស់តថាគត រដិបរដុប ដូចជាលំពង់ឈើដែលវល្លិព័ទ្ធវេញ ព្រោះមានអាហារតិចនោះឯង ។ របៀបនៃឆ្អឹងជំនីទាំងឡាយរបស់តថាគត ក៏រគីមរគាម ដូចជាបង្កង់នៃសាលាចាស់ដ៏រគីមរគាម ព្រោះមានអាហារតិចនោះឯង ។ ប្រស្រីភ្នែកក្នុងរណ្ដៅភ្នែករបស់តថាគត ក៏ជ្រៅខូងចុះទៅ ដូចក្រពេញទឹក ក្នុងអណ្ដូងទឹកជ្រៅ ដ៏ជ្រៅខូងចុះទៅ ព្រោះមានអាហារតិចនោះឯង ។ ស្បែកក្បាល ឰដ៏ក្បាល របស់តថាគត ដែលអាហារតិចនោះពាល់ត្រូវហើយ ក៏ស្វិតជ្រីវដូចជា ផ្លែនខោងព្រៃ ដែលគេកាត់អំពីខ្ចី លុះខ្យល់និងកំដៅថ្ងៃពាល់ត្រូវហើយ ក៏ស្វិតជ្រីវដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវលើឆ្អឹងខ្នងទៅវិញគិតថា អាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវលើស្បែកពោះទៅវិញ ម្នាលអគ្គិវេស្សនៈ ព្រោះថាស្បែកពោះរបស់តថាគតជាប់នឹងឆ្អឹងខ្នង ព្រោះមានអាហារតិចនោះឯង ។ ម្នាល

អគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងបន្ទោបង់នូវវច្ចៈឬទឹកមូត្រ ក៏ដួលផ្កាប់ក្នុងទីនោះ ព្រោះមានអាហារតិចនោះឯង។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ធ្វើកាយនេះឱ្យស្រួលបួលដុសខ្លួនប្រាណដោយដៃ ម្នាលអគ្គិវេស្សនៈ កាលបើតថាគតនោះដុសខ្លួនប្រាណដោយដៃ រោមទាំងឡាយមានគល់ស្អុយ ក៏ធ្លាក់ចុះអំពីកាយ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ មនុស្សទាំងឡាយបានឃើញតថាគត ហើយពោលពាក្យយ៉ាងនេះថា ព្រះសមណគោតម មានសម្បុរខ្មៅ ។ មនុស្សពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតមមិនខ្មៅទេ ព្រះសមណគោតម មានសម្បុរសណ្តែកបាយ ។ មនុស្សពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនមែនសម្បុរខ្មៅ មិនមែនសម្បុរសណ្តែកបាយទេ ព្រះសមណគោតមមានសម្បុរស្បែកប្រផេះ ។ ម្នាលអគ្គិវេស្សនៈ សម្បុរស្បែករបស់តថាគត បរិសុទ្ធផូរផង់ដល់ម្លោះ ក៏ត្រឡប់ជាអាប់អន់ ព្រោះមានអាហារតិចនោះឯង ។

(៤៥) ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ជនទាំងឡាយណាមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី

ក្នុងអតីតកាល បានរងនូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនលើសលប់ជាងនេះទៅទៀតទេ ។ ជនទាំងឡាយណាមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអនាគតកាលនឹងរងនូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនលើសលប់ជាងនេះទៅទៀតទេ ។ ជនទាំងឡាយណាមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាល ឥឡូវនេះ តែងរងនូវទុក្ខវេទនាដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនមានលើសលប់ជាងនេះទៅទៀតទេ ។ ចំណែកខាងអាត្មាអញ មិនទាន់បានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម ដែលអាចកំចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ដោយទុក្ករកិរិយា ដ៏ផ្សាខ្លោចនេះនៅឡើយ ។ ផ្លូវដទៃប្រព្រឹត្តទៅដើម្បីត្រាស់ដឹង គប្បីមានដែរឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលដែលអាត្មាអញអង្គុយនៅក្រោមម្លប់នៃដើមព្រីងដ៏ត្រជាក់ ក្នុងកិច្ចការរបស់សក្យរាជជាបិតា ក៏ធ្លាប់បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌

ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនឹងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ហើយសម្រេចសម្រាន្តនៅ ឱហ្ន៎ នុ៎ះឯងជាផ្លូវនៃកាត្រាស់ដឹងហើយទេដឹង ។ ម្នាលអគ្គិវេស្សនៈ វិញ្ញាណជាគ្រឿងរឭកតាមនូវស្មារតី ក៏កើតឡើងដល់តថាគតនោះថា ផ្លូវនុ៎ះឯងហើយ ជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណាក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញខ្លាចសេចក្តីសុខនោះឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណាក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញមិនខ្លាចសេចក្តីសុខនោះទេ ។

(៤៦) ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា បុគ្គលមានកាយដល់នូវអាការស្គាំងស្គមក្រៃលែងយ៉ាងនេះ មិនងាយបាននូវសេចក្តីសុខនោះទេ បើដូច្នោះ គួរតែអាត្មាអញបរិភោគនូវអាហារដ៏គ្រោតគ្រាតគឺបាយនិងនំវិញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយនិងនំ ។

ម្នាលអគ្គិវេស្សនៈ សម័យនោះឯង ភិក្ខុទាំង ៥ រូប តាមមកបំរើតថាគត ដោយគិតថាព្រះសមណគោតមរបស់យើង នឹងបានត្រាស់នូវធម៌ណា លោកនឹងប្រាប់នូវធម៌នោះដល់យើងទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ ព្រោះហេតុតែតថាគតបរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយនិងនំ ក្នុងកាលណា ភិក្ខុទាំង ៥ រូបនោះ លះបង់រត់ចោលតថាគតក្នុងកាលនោះ ដោយគិតថា ព្រះសមណគោតមប្រកបដោយល្មោភច្រើន ដោះចោលព្យាយាម ត្រឡប់ទៅដើម្បីសេចក្តីល្មោភច្រើន ។

(៤៧) ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះឯង បរិភោគនូវអាហារដ៏គ្រោតគ្រាតហើយ ក៏មានកម្លាំង បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈានដែលប្រកប ដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងាត់នោះ ក៏សម្រេចសម្រាន្ត ទៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ លុះតថាគតរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏បានដល់នូវទុតិយជ្ឈាន ជា

ធម្មជាតិកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្កៈនិងវិចារៈមានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន... ក៏បានដល់នូវតតិយជ្ឈាន ...បានដល់នូវចតុត្ថជ្ឈាន ... ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ កាលដែលចិត្តរបស់តថាគត ខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ( ដោយអំណាចឈានទាំង ៤ ) ដោយប្រការដូច្នេះហើយ តថាគតបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរលឹក ឃើញជាតិ ១ ខ្លះ ជាតិ ២ ខ្លះ ។បេ។ រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការគឺរូបនិងអាហារជាដើម ព្រមទាំងឧទ្ទេសគឺ ឈ្មោះនិងគោត្រកូលជាដើម ដោយប្រការដូច្នេះ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ១ នេះឯង តថាគតបានឃើញហើយក្នុងបឋមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ

វិជ្ជាក៏កើតឡើង សេចក្ដីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាម ញ៉ាំងកិលេសឱ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ១ នោះឯង ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

(៤៨) កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីសត្តចុតូបបាតញ្ញាណ ។ តថាគតនោះ មានចក្ខុដូចជាទិព្វដ៏ស្អាតកន្លងហួសចក្ខុរបស់មនុស្សធម្មតា ក៏បានឃើញនូវពួកសត្វដែលច្យុតដែលកើតឡើង ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ រូបអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ មួយវិញទៀត តថាគតដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ។បេ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ២ នេះឯង តថាគតបានឃើញហើយក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្ដីងងឹតខ្ចាត់បាត់ទៅ

ហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញុំាងកិលេសឱ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

(៤៩) កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់មិនមានទីទួលពោលគឺកិលេស ប្រាកចាកឧក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាម អារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះបានដឹងច្បាស់តាមពិតថា នេះជាទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាហេតុនាំឱ្យកើតទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅ កាន់ទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ បានដឹងច្បាស់ តាមពិតថា នេះជាធមិនាំឱ្យកើតអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលតថាគត

នោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរបស់តថាគតរួចចាក កាមាសវៈផង ចិត្តរបស់តថាគតរួចចាកភវាសវៈផង ចិត្តរបស់តថាគតរួចចាកអវិជ្ជាសវៈផង ។បេ។ តថាគតដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បី សោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ៣ នេះឯង តថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្ដីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឱ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

ក្នុងកាលឥឡូវនេះ តថាគតជាព្រះសម្ពុទ្ធ ព្រះនាមគោតម សម្រេចដោយការតាំងព្យាយាម ដល់នូវសម្ពោធិញ្ញាណដ៏ឧត្ដមនាមណ្ឌលពោធិព្រឹក្ស តថាគតជាព្រះជិនស្រី បានញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅក្នុងព្រៃឥសិបតនៈ ទៀបក្រុងពារាណសី តថាគតជាគោតមសម្ពុទ្ធជាទីពឹងនៃសត្វទាំងពួង ។

# អារម្ភកថា

សៀវភៅនេះ កើតឡើងដោយអាស្រ័យហេតុដូចមានខាងក្រោមនេះ :

១- កាលពីក្នុងព.ស ២៥៤៨ ជាលើកទី ១ ខ្ញុំមានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានថតចម្លងសៀវភៅឈ្មោះ ទសបារមីកថា របស់ព្រះឧត្តមមុនី អ៊ុម-ស៊ូ អធិបតីរងក្រុមជំនុំព្រះត្រៃបិដក បានសម្រេចជាធម្មទានរួចម្តងហើយ ។

កាលពីព.ស ២៥៤៨ ជាលើកទី ២ ខ្ញុំបានប្រមូលឯកសារ លំនាំអដ្ឋបទរឿង ចរិយាបិដក និងប្រភេទនៃទុក្ករកិរិយាពីក្នុងគម្ពីរព្រះត្រៃបិដកលេខ ៧៧ និងបិដកលេខ ២២ យកមកថត ចម្លងរៀបរៀងជាសៀវភៅឈ្មោះ បារមីកថា ពុទ្ធាបទាន បានសម្រេចជាធម្មទានរួចហើយ ។

កាលពីក្នុងព.ស ២៥៤៨ ជាលើកទី ៣ ខ្ញុំបានប្រមូលឯកសារអដ្ឋបទធម៌ ស្ថាន ៥ យ៉ាង ពីក្នុងគម្ពីរព្រះត្រៃបិដក លេខ ៤៤ យកមកថតចម្លងរៀបរៀងជាសៀវភៅ ឈ្មោះ អភិណ្ហប្បច្ចវេក្ខណធម៌ បានសម្រេចជាធម្មទានរួចម្តងហើយ ។

២- ដោយខ្ញុំយល់ឃើញថា សៀវភៅទាំង ៣ នេះមាន អក្សរ តូចផង និងមិនសូវច្បាស់ថែមទៀត លំបាកដល់ចាស់ ៗ គាត់មើល ខ្ញុំក៏បាន

សម្រេចចិត្តយកសៀវភៅទាំង ៣ នេះ ឱ្យកូនខ្ញុំសរសេរជាអក្សរថ្មី លុះសរសេររួចស្រេចហើយ ខ្ញុំក៏យកទៅប្រគេនព្រះគ្រូ **គម្ពីរត្ថេរោ យី-ទិត** ព្រះវិនយធរគណ ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងលោកម្ចាស់គ្រូ **មេត្តាបាលោ ទីម-សឿត** ចៅអធិការវត្តនិគ្រោធវ័ន ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ព្រមទាំងព្រះថេរៈជាច្រើនអង្គដែលជាអ្នកឈ្លាសវៃក្នុងព្រះធម៌ សូមឱ្យលោកជួយពិនិត្យផ្ទៀងផ្ទាត់ មើលថែមទៀត លោកក៏យកចិត្តទុកដាក់ជួយពិនិត្យឱ្យឃើញថាត្រឹមត្រូវតាមច្បាប់ដើម ឥតមានទាស់ខុសអ្វីឡើយ ទើបខ្ញុំយកឯកសារនេះ ទៅចាត់ចែងបោះពុម្ពចែកជាធម្មទានតាមសេចក្ដីជ្រះថ្លា ។

ដោយអំណាចនៃបុណ្យកុសល ដែលកើតអំពីធម្មទាននេះ សូមជាបច្ច័យបានប្រកបដោយសតិ បញ្ញា ស្មារតី ជាសម្មាទិដ្ឋិ បានសុខក្នុងលោកទាំងពីរ រហូតដល់អវសានជាតិ សូមកើតមានដល់លោកអ្នកមានគុណ មានមាតា បិតាជាដើមផង ដល់សព្វសត្វទាំងអស់ផង ដល់ខ្ញុំព្រះករុណាផង ជាពិសេសដល់លោកអ្នកអានគ្រប់រូបទាំងអស់ ។

ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង"

១២ រោច ខែពិសាខ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២

ខ្ញុំព្រះករុណា អាត្មាភាព មុនីកោសល្យ នៅ-ហៃឡុន

# បញ្ជីមាតិកាបារមីកថា ពុទ្ធាបទាន

មាតិកាបារមីកថា ពុទ្ធាបទាន ទំព័រ

បញ្ជីមាតិកាបារមីកថា ពុទ្ធាបទាន. ... ... ... ... ... គ

សុមេធកថា ... ... ... ... ... ... ... ... ... ... ... ១

១. ទានបារមី

អកិត្តិចរិយា ទី ១ . ... ... ... ... ... ... ... ... ... ១៤

សង្ខព្រាហ្មណចរិយា ទី ២ ... ... ... ... ... ... ... ១៦

កុរុធម្មចរិយា ទី ៣ ... ... ... ... ... ... ... ... ... ១៧

មហាសុទស្សនចរិយា ទី ៤.. ... ... ... ... ... ... ១៩

មហាគោវិន្ទចរិយា ទី ៥ . ... ... ... ... ... ... ... ២១

នេមិរាជចរិយា ទី ៦ . ... ... ... ... ... ... ... ... ២២

ចន្ទកុមារចរិយា ទី ៧. ... ... ... ... ... ... ... ... ២៣

សិវិរាជចរិយា ទី ៨ .. ... ... ... ... ... ... ... ... ២៤

វេស្សន្តរចរិយា ទី ៩... ... ... ... ... ... ... ... ... ២៧

សសបណ្ឌិតចរិយា ទី ១០ .. ... ... ... ... ... ... ៣៦

## ២. សីលបារមី

សីលវនាគចរិយា ទី ១ ... ... ... ... ... ... ... ... ៤០

ភូរិទត្តចរិយា ទី ២. ... ... ... ... ... ... ... ... ... ៤២

ចម្បេយ្យចរិយា ទី ៣ ... ... ... ... ... ... ... ... ៤៤

ចូឡពោធិចរិយា ទី ៤. ... ... ... ... ... ... ... ... ៤៥

មហិសរាជចរិយា ទី ៥ ... ... ... ... ... ... ... ... ៤៧

រុរុមិគចរិយា ទី ៦.. ... ... ... ... ... ... ... ... ... ៤៩

មាតង្គចរិយា ទី ៧. ... ... ... ... ... ... ... ... ... ៥១

ធម្មទេវបុត្តចរិយា ទី ៨... ... ... ... ... ... ... ... ៥២

ជយទិសចរិយា ទី ៩ .. ... ... ... ... ... ... ... ... ៥៣

សង្ខបាលចរិយា ទី ១០ .. ... ... ... ... ... ... ... ៥៥

## ៣. នេក្ខម្មបារមី

យុធញ្ជយចរិយា ទី ១ ... ... ... ... ... ... ... ... ៥៨

សោមនស្សចរិយា ទី ២... ... ... ... ... ... ... ... ៥៩

អយោឃរចរិយា ទី ៣ .. ... ... ... ... ... ... ... ៦២

ភីសចរិយា ទី ៤ ... ... ... ... ... ... ... ... ... ... ៦៤

សោណនន្ទបណ្ឌិតចរិយា ទី ៥... ... ... ... ... ... ៦៦

មូគផក្ខចរិយា ទី ៦ ... ... ... ... ... ... ... ... ... ៦៧

កបិលរាជចរិយា ទី ៧ ... ... ... ... ... ... ... ... ៧០

សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨ .. ... ... ... ... ... ៧០

វដ្តកបោតកចរិយា ទី ៩... ... ... ... ... ... ... ... ៧១

មច្ឆរាជចរិយា ទី ១០. ... ... ... ... ... ... ... ... ៧៣

កណ្ហទីបាយនចរិយា ទី ១១. ... ... ... ... ... ... ៧៥

សុតសោមចរិយា ទី ១២. ... ... ... ... ... ... ... ៧៧

សុវណ្ណសាមចរិយា ទី ១៣ .. ... ... ... ... ... ... ៧៨

ឯករាជចរិយា ទី ១៤. ... ... ... ... ... ... ... ... ៧៩

មហាលោមហំសចរិយា ទី ១៥. ... ... ... ... ... ៨០

សមោធានកថា. ... ... ... ... ... ... ... ... ... ... ៨៣

ប្របេភេទនៃទុក្ករកិរិយា ... ... ... ... ... ... ... ... ៨៧

# អ្នកមានឧបការៈ

១- លោកម្ចាស់ គួ-សុភាព

២- លោកម្ចាស់  អ៊ិន-សំអឿន

៣- លោកម្ចាស់ ភួង-សុវណ្ណ

៤- លោកម្ចាស់  ឆាយ-កន

៥- លោកម្ចាស់  គង់-សុមិត្ត

៦- លោកម្ចាស់ សួរ-ស៊ុម

៧- សាមណេរ ស៊ឹម-ស៊ីសាមុត

៨- យុវសិស្ស នៅ-ពីឡុត

៩- ឧបាសិកា ហុង-ចេង